**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royal de Droit et des Sciences Economiques

Royal Unviersity of  Law and Economics

## សារណាបញ្ចប់ការសិក្សា

# មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០២០

ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ៖ **ថន សីហា**

**កញ្ញា. សុខ ម៉ី**

សាស្ត្រាចារ្យណែនាំ

លោកស្រី **ទី សុឃីតា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **ខន សីហា** និង **ក.សុខ មុី** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតសាស្រ្ត ឆ្នាំទី៤ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៦-២០២០។ ក្នុងនាមយើងខ្ញុំជាយុវជនជំនាន់ក្រោយ ដែលជាទំពាំងស្នងឬស្សី និង ជាសសរទ្រូងប្រទេសជាតិ យើងខ្ញុំបានស្រាវជ្រាវ និង សរសេរជាសារណាក្រោមប្រធានបទស្តីពី "**មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍**"។

យើងខ្ញុំសូមធ្វើការថ្លែងអំណរគុណ និង សំដែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះ៖

**លោកឪពុក អ្នកម្តាយ**ជាទីគោរពស្រឡាញ់នៃកូន ដែលបានផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មាន ប្រៀនប្រដៅ ណែនាំផ្តល់ដំបូន្មាន និង ផ្តល់ក្តីស្រឡាញ់ចំពោះកូនតាំងពីតូចរហូតដល់ធំពេញវ័យ ហើយរូបលោកបានលោះបង់ គ្រប់បែបយ៉ាង នូវកម្លាំងកាយ កម្លាំងចិត្ត ទាំងផ្នែកបញ្ញា និង ស្មារតី លើកទឹកចិត្តក្នុងការខិតខំសិក្សារៀនសូត្រ និង ផ្តល់ជា ថវិកា សម្ភារៈប្រើប្រាស់ក្នុងការសិក្សារៀនសូត្រផងដែរ។ គុណូបការៈ និង ព្រហ្មវិហាធម៌ របស់លោកអ្នកមានគុណ ចំពោះយើងខ្ញុំពិតជាធំធេង និង រកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ កូនមិនអាចបំភ្លេចនូវគុណធម៌ និង ព្រហ្មវិហារធម៌របស់លោកអ្នកមានគុណបានទេ ហើយនឹងស្ថិតនៅក្នុងចិត្តកូនជានិច្ចដរាប។

ទន្ទឹមគ្នានេះដែរ យើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណ ចំពោះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលលោកបានដាក់ចេញនូវគោលនយោបាយល្អៗ និង ប្រកបដោយប្រសិទ្ធិភាពខ្ពស់ក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

ជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់ **ឯឧត្តមសាកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង វិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំអប់រំអស់ពីសមត្ថភាពក្នុងការផ្ទេរ ចំណេះដឹង បទពិសោធន៍ ឯកសារ សិក្សាស្រាវជ្រាវ ដល់យើងខ្ញុំក្នុងការសិក្សារៀនសូត្រ។

ជាពិសេស សូមថ្លែង អំណរគុណយ៉ាងជ្រាលជ្រៅ ដល់**លោកស្រី សាស្រ្តាចារ្យ ទី សុឃីតា** ដែលជាសាស្រ្តាចារ្យ ណែនាំ ដល់ពួកយើងខ្ញុំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃសម្រាប់ធ្វើការបង្ហាត់បង្ហាញ ណែនាំ កែតម្រូវ ផ្តល់ការប្រឹក្សា និង អនុសាសន៍ល្អៗ ដែលធ្វើឲ្យកិច្ចដំណើរការ នៃការស្រាវជ្រាវ និង ចងក្រងនូវឯកសារសារណានេះ ប្រកបដោយលទ្ធផលល្អ។

មួយវិញទៀតសូមថ្លែងអំណរគុណ ចំពោះ លោកតា លោកយាយ អ៊ំប្រុស អ៊ំស្រី លោកពូ អ្នកមីង បង ប្អូន សិស្សច្បង មិត្តភក្តិទាំងអស់ដែលបានជួយលើទឹកចិត្ត និង ផ្តល់ជាមតិយោបល់ល្អៗ ជាច្រើន ក៏ដូចជាចែករំលែកនូវបទពិសោធន៍នានា ដល់ពួកយើងខ្ញុំ ក្នុងការសរសេរសារណា។

ជាចុងបញ្ចប់ យើងខ្ញុំ សូមឲ្យវត្ថុស័ក្តសិទ្ធិទាំងអស់ ក្នុងលោកតាមថែរក្សា ការពារ និង ប្រសិទ្ធិពរជ័យ សិរីសួស្តីដល់ **លោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** ឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អកាយសម្បទារឹងមាំ អាយុ យឺនយូ ជោគជ័យគ្រប់ភារកិច្ច និង ជួបតែពុទ្ធិពរ ទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀតឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីទទួលបាន ការសិក្សាអស់រយៈពេល ៤ឆ្នាំកន្លងមក ក្នុងមុខវិជ្ជាផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំទាំងពីរនាក់ បានសិក្សាស្រាវជ្រាវឯកសារផ្សេងៗ ជាច្រើន ទាំងផ្នែកនីតិឯកជន និង ផ្នែកនីតិសាធារណៈ ដែលជាហេតុនាំឲ្យ យើងខ្ញុំ យល់ថា ប្រជាជនខ្មែរ មានចំណុចខ្វះខាតជាច្រើន ដូចជាការរៀបអាពាហ៍ពិពាហ៍ដែលមានលក្ខណៈផ្ទុយនឹងច្បាប់ និង មិនមានអានុភាពទៅលើអាពាហ៍ពិពាហ៍។ មួយវិញទៀតអាពាហ៍ពិពាហ៍ដែល ឪពុក ម្តាយ ឬសាមីខ្លួនមួយចំនួនបានគិត អំពីផលប្រយោជន៍ ដែលទទួលបានពីការរៀបអាពាហ៍ពិពាហ៍ជាធំ ដោយមិនបានគិតពីផលប៉ះពាល់។

ការរៀបចំសរសេរសារណា នេះឡើង ក្នុងគោលបំណងដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ និង ដើម្បីចូលរួមចំណែកក្នុងការជួយសង្គមជាតិ យើងខ្ញុំក៏បានស្រាវជ្រាវសារណានេះឡើង ដោយទាក់ទងទៅនឹងផ្នែកនីតិឯកជន ដែលប្រធានបទស្តីពី “**មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍**” ដើម្បីយកមកធ្វើជាកម្មវត្ថុក្នុងការស្រាវជ្រាវ។ ការជ្រើសរើសនេះ គឺដើម្បីឲ្យប្រជាពលរដ្ឋខ្មែរ បានយល់ដឹងកាន់តែច្បាស់អំពីមូលហេតុដែលនាំឲ្យមានការមោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍ ព្រមទាំងយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិរបស់ខ្លួនក្នុងការ ទាមទារឲ្យមោឃភាព និង លុបចោលអាពាហ៍ពិពហ៍ណាដែលផ្ទុយនឹងច្បាប់ ឬ ដោយការបង្ខិតបង្ខំ បោកប្រាស់ ឬ អាពាហ៍ពិពាហ៍ដែលគ្មានឆន្ទៈ និង តាមគ្រប់រូបភាពផ្សេងៗទៀត។ នៅក្នុងសារណាមួយនេះផងដែរ។ យើងខ្ញុំបានស្រាវជ្រាវ និង ដកស្រង់ចេញពីឯកសារផ្សេងៗ ដែលអាចជាគំនិត និង ចំណុចសំខាន់ៗ ដែលទាក់ទងនឹងប្រធានបទ។ ជាពិសេសយើងខ្ញុំក៏បានទទួលការណែនាំពីលោកស្រីសាស្ត្រាចារ្យ និង ផ្តល់ជាគំនិតយោបល់ចំពោះប្រធានបទនេះ។

យើងខ្ញុំសង្ឃឹមថា សារណានេះនឹងអាចជួយដល់សិស្ស និស្សិត មិត្តអ្នកអាន និង ប្រជាពលរដ្ឋខ្មែរ គ្រប់រូបឲ្យយល់ដឹងពីចំណុចមួយចំនួនដែលទាក់ទង និង ផ្នែកនីតិឯកជន ជាពិសេសគឺ មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍។

ជាចុងបញ្ចប់ យើងខ្ញុំសូមអភ័យទោសទុកជាមុនរាល់ចំណុចខ្វះខាតមួយចំនួនដែលកើតឡើង ក្នុងសារណាយើងខ្ញុំ ដូចជាការខុសឆ្គង ទៅលើពាក្យពេចន៍ ខ្លឹមសារ អត្ថន័យ ឬ អក្ខរាវិរុទ្ធ ទាំងឡាយ នៅក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយក្តីអនុគ្រោះ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........................................ ១


## ជំពូកទី ១

## មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍


ផ្នែកទី១៖ មោឃភាពអាពាហ៍ពិពាហ៍ ........................................ ៤

១.១. មោឃភាពដាច់ខាត ........................................ ៥

១.១.១. ការភាន់ច្រឡំលើមនុស្ស ........................................ ៥

១.១.២. ការបង្ខិតបង្ខំ ........................................ ៥

១.២. មោឃភាពមិនដាច់ខា ........................................ ៦

១.២.១. ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ........................................ ៦

១.២.២. ភាគីមិនបានជូនដំណឹងជាសាធារណៈ ........................................ ៦

១.២.៣. ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ........................................ ៧

១.២.៤. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ........................................ ៧

ផ្នែកទី២៖ ការលុបចោលអាពាហ៍ពិពាហ៍ ........................................ ៧

២.១. អាពាហ៍ពិពាហ៍ដែលភាគីមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ ........................................ ៨

២.២. អាពាហ៍ពិពាហ៍ធ្វើនៅក្នុងអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ ........................................ ៩

២.៣. ទ្វេពន្ធភាព ........................................ ៩

២.៤. អាពាហ៍ពិពាហ៍រវាងញាតិលោហិត ........................................ ១០

២.៥. អាពាហ៍ពិពាហ៍រវាងញាតិពន្ធ ........................................ ១១

២.៦. អាពាហ៍ពិពាហ៍ដោយការឆបោក ........................................ ១២

២.៧. អាពាហ៍ពិពាហ៍ដោយការគំរាមកំហែង ........................................ ១៣

ផ្នែកទី៣៖ អ្នកមានសិទ្ធិទាមទារឲ្យមោឃភាព និង លុបចោលអាពាហ៍ពិពាហ៍ ........................................ ១៣

៣.១. អ្នកមានសិទ្ធិទាមទារឲ្យមោឃភាពអាពាហ៍ពិពាហ៍ ........................................ ១៣

៣.១.១. សហព័ទ្ធ ........................................ ១៤

៣.១.២. តំណាងអយ្យការ ............ ១៤
៣.១.៣. ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ ............ ១៤
៣.២. អ្នកមានសិទ្ធិទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ............ ១៥
៣.២.១. សហព័ទ្ធ ............ ១៥
៣.២.២. ញាតិសណ្ដានរបស់ភាគី ............ ១៥
៣.២.៣. តំណាងអយ្យការ ............ ១៦

## ជំពូកទី២

## នីតិវិធីមោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

ផ្នែកទី១៖ យុត្តាធិការតុលាការ ............ ១៨
១.១ ការដាក់ពាក្យបណ្ដឹង ............ ១៩
១.១.១. របៀបដាក់ពាក្យបណ្ដឹង ............ ១៩
១.១.២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង ............ ១៩
១.២. ការបង់ពន្ធប្រាក់ប្រដាប់ក្ដី ............ ២០
១.២.១. ប្រភេទប្រាក់ប្រដាប់ក្ដី ............ ២០
១.២.២. បន្ទុកនៃប្រាក់ប្រដាប់ក្ដី ............ ២១
១.៣. ការចាត់ចែងពាក្យបណ្ដឹង ............ ២១
១.៣.១. ការទទួលពាក្យបណ្ដឹង ............ ២២
១.៣.២. ការពិនិត្យពាក្យបណ្ដឹង ............ ២២
១.៣.៣. ការបញ្ជូនពាក្យបណ្ដឹង ............ ២៣
ផ្នែកទី២៖ ការវិនិច្ឆ័យនៅក្នុងការធ្វើមោឃភាពអាពាហ៍ពិពាហ៍ និង ការលុបចោលអាពាហ៍ពិពាហ៍ ............ ២៥
២.១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ............ ២៥
២.២. ការសម្រេចសេចក្ដី(សាលក្រម) ............ ២៦

## ជំពូកទី៣

## អានុភាពនៃមោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

ផ្នែកទី១៖ អានុភាពនៃមោឃភាពអាពាហ៍ពិពាហ៍ ............ ២៧

១.១. អានុភាពចំពោះទំនាក់ទំនងញាតិ.......... ២៧
១.២. អានុភាពចំពោះទំនាក់ទំនងបុត្តភាព.......... ២៧
១.២.១. ការសន្មតបិតុភាព.......... ២៧
១.២.២. អំណាចមេបា.......... ២៨
១.២.៣. សោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូន.......... ២៨
១.៣. អានុភាពចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ.......... ២៨
១.៣.១. ការបែងចែកទ្រព្យសម្បត្តិរួម.......... ២៩
១.៣.២. ការទទួលខុសត្រូវលើបំណុល.......... ២៩
ផ្នែកទី២៖ អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍.......... ៣០
២.១. សំណងនៃការខូចខាត.......... ៣០
២.២. អានុភាពចំពោះបុគ្គល.......... ៣១
២.២.១. អានុភាពចំពោះសាមីជន.......... ៣១
២.២.២. អានុភាពចំពោះបុត្តភាព.......... ៣១
២.៣. អានុភាពទៅលើទ្រព្យសម្បត្តិ.......... ៣២
២.៣.១. ការបែងចែកទ្រព្យសម្បត្តិរួម.......... ៣២
២.៣.២. ការទទួលខុសត្រូវលើបំណុល.......... ៣៤
**សេចក្តីសន្និដ្ឋាន**.......... ៣៦
**អនុសាសន៍**.......... ៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ប្រសិនបើយើង ពិនិត្យទៅលើគ្រប់បណ្តាប្រវត្តិសាស្ត្រ នៃប្រទេសនីមួយៗ នៅលើសកលលោកនេះ នឹងឃើញថាគ្រប់ជាតិសាសន៍ទាំងអស់ សុទ្ធតែមានប្រពៃណី ទំនៀមទំលាប់របស់ខ្លួនជាមូលដ្ឋាន។ ប្រទេសណាដែលមានប្រពៃណី ទំនៀមទំលាប់ចំណាស់ជាងគេ រីកលូតលាស់ជាងគេ ត្រូវបានគេចាត់ទុកថា ជាប្រទេសដែលរុងរឿងជាងគេ នាសសម័យកាលនោះ។ នៅក្នុងឯកសារប្រវត្តិសាស្ត្រដែលបានបន្សល់ទុកសបញ្ជាក់ឲ្យឃើញថាខ្មែរធ្លាប់មានវប្បធម៌ អរិយធម៌ ខ្ពង់ខ្ពស់ និង ល្បីល្បាញពេញពិភពលោក ហើយបានបន្សល់ទុករហូតមកដល់សព្វថ្ងៃនេះ ដូចជាប្រាង្គប្រាសាទ ព្រៃកជីក វត្ថុបុរាណ រូបចម្លាក់ និង របស់ជាច្រើនផ្សេងៗទៀត។ អ្វីដែលពិសេសជាងនេះទៅទៀតនោះ ប្រជាពលរដ្ឋខ្មែរនៅតែប្រកាន់យ៉ាងខ្ជាប់ខ្ជួន នូវប្រពៃណីទំនៀមទំលាប់ក្នុងការប្រារព្ធពិធីផ្សេងៗក្នុងនោះផងដែរ ក៏មានពីធីរៀបអាពាហ៍ពិពាហ៍ដែលគ្រប់គ្នាហៅថា ការរៀបអាពាហ៍ពិពាហ៍។ ពីសម័យបុរាណរបៀបរបបនៃការរៀបអាពាហ៍ពិពាហ៍ មានពិធីដែលត្រូវរៀបចំ ជាច្រើនដំណាក់កាល ក្នុងនោះមានដូចជា ពិធីចៃចូវពិធីស្តីដណ្តឹង ពិធីភ្ជាប់ពាក្យ ឬ កំជាប់ពាក្យ ទើបឈានដល់ពិធីរៀបអាពាហ៍ពិពាហ៍ ឬ មានការរៀបចំតាមរបៀបផ្សេងៗទៀត ទៅតាមតំបន់។

ដោយឡែកនាពេលបច្ចុប្បន្ននេះ ដោយសារតែមានការរីកចម្រើន និងមានការវិវឌ្ឍយ៉ាងខ្លាំងខ្លាលើបញ្ហាសិទ្ធិបុគ្គល ទើបបញ្ហានៃទំនៀមទំលាប់ត្រូវបានក្លាយទៅជាចម្រើសទីពីរលើការកំណត់អំពីការបង្កើតទំនាក់ទំនងញ្ញាតិ។ ជាក់ស្តែងពាក់ព័ន្ធនឹងការបង្កើតចំណងអាពាហ៍ពិពាហ៍នៅក្នុងសង្គមខ្មែរយើង រដ្ឋាភិបាលគឺទទួលស្គាល់តែចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់តែប៉ុណ្ណោះ គឺការរៀបអាពាហ៍ពិពាហ៍ដោយមានការចុះលិខិតអាពាហ៍ពិពាហ៍។ ដូច្នេះដើម្បីអាចទទួលបាននូវលិខិតអាពាហ៍ពិពាហ៍លុះត្រាតែបណ្តាភាគីនៃអាពាហ៍ពិពាហ៍គោរពបានទៅនឹងលក្ខខណ្ឌផ្សេងៗដែលកំណត់ដោយវិធាននៃច្បាប់អាពាហ៍ពិពាហ៍ដូចជា លក្ខខណ្ឌអាយុ ភេទ សេរីភាពនៃឆន្ទៈក្នុងរៀបអាពាហ៍ពិពាហ៍ ។ល។

ផ្ទុយមកវិញក្នុងករណីដែលចំណងអាពាពិហ៍ពាហ៍នោះបង្កើតឡើងដោយមានការបំពានទៅលើវីធានគតិយុត្តិដែលពាក់ព័ន្ធនោះ លិខិតអាពាហ៍ពិពាហ៍នោះ អាចត្រូវប្រឈមនឹងការធ្វើមោឃភាព ឬក៏ត្រូវបានលុបចោលដោយសារការទាមទាររបស់ភាគីដែលពាក់ព័ន្ធ ឬអាជ្ញាធរសាធារណៈផងដែរ។
យ៉ាងណាមិញដោយសារតែប្រធានបទនៃការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំផ្តោតតែទៅលើ ការសុំមោឃភាព និងលុបចោលអាពាហ៍តែប៉ុណ្ណោះ ដូច្នេះនៅទំព័រនឹងផ្នែកជាបន្តបន្ទាប់ទៅទៅទៀតនេះ ក្រុមយើងខ្ញុំនឹងធ្វើការបកស្រាយលំអិតទៅលើចំណុចដូចខាងក្រោម៖

**ជំពូកទី១៖ មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍**

**ជំពូកទី២៖ នីតិវិធីមោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍**

**ជំពូកទី៣៖ អានុភាពនៃមោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍**

ដោយយើងខ្ញុំ និងធ្វើការបកស្រាយដោយលំអិតនៅតាមជំពូកពាក់ព័ន្ធនីមួយៗ តាមផ្នែកបន្តបន្ទាប់ទៀត។

# ជំពូកទី ១

# មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

នៅក្នុងសង្គមខ្មែរ បុរស នារី នៅពេល ដល់វ័យរៀបអាពាហ៍ពិពាហ៍ ឪពុកម្ដាយតែងតែរៀបចំទុកដាក់កូនចៅឲ្យមានគូស្រករ ដើម្បីបង្កើតគ្រួសារបន្តពូជវង្សត្រកូលតាមរយៈការរៀបចំពិធីអាពាហ៍ពិពាហ៍ ដែលគោរពទៅតាមប្រពៃណីទំនៀមទម្លាប់ខ្មែរ។ ការរៀបអាពាហ៍ពិពាហ៍ ជាចំណងសម្ព័ន្ធរវាងបុរស និង នារី ដូច្នេះ បុរស និង នារី ចាំបាច់ពេញវ័យ ទាំងផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ផ្លូវកាយ ផ្លូវចិត្ត ព្រមទាំងបញ្ញាស្មារតីផង។ ការរៀបចំអាពាហ៍ពិពាហ៍ គឺជាការប្រារព្ធពិធីដែលមានការចូលរួមពីភ្ញៀវកិត្តិយសសាច់ញាតិ ដើម្បីជាការទទួលដឹងឮថា បុរស និង នារីមួយគូរនេះបានព្រមព្រៀងស្រឡាញ់គ្នា សុខចិត្តរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធរហូតដល់ចាស់ស្លាប់។ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយដើម្បីមួយធ្វើឡើងដោយ បុរសម្នាក់ និង ស្ត្រីម្នាក់ ដែលប្ដេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន។ អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែអាពាហ៍ពិពាហ៍នោះ ធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់[1]។ ជាការកំណត់តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាយើង ដើម្បីឲ្យអាពាហ៍ពិពាហ៍មួយស្របទៅតាមការកំណត់នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាយើង គឺត្រូវគោរពនូវលក្ខខណ្ឌមួយចំនួនដូចជា លក្ខខណ្ឌគ្រឹះ និង លក្ខខណ្ឌទម្រង់ ឬ លក្ខខណ្ឌដែលតម្រូវតាមការកំណត់របស់ច្បាប់ នៃអាពាហ៍ពិពាហ៍។ ប្រសិនបើអាពាហ៍ពិពាហ៍ មិនបានគោរពទៅតាមលក្ខខណ្ឌច្បាប់ទេ អាពាហ៍ពិពាហ៍នោះ នឹងត្រូវទទួលរងទណ្ឌកម្ម ហើយទណ្ឌកម្មទាំងនោះ អាចកើតឡើង មុខពេលរៀបអាពាហ៍ពិពាហ៍ និង ក្រោយពេលរៀបអាពាហ៍ពិពាហ៍។

ក្នុងករណីមុនពេលរៀបអាពាហ៍ពិពាហ៍ ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានបានទទួលបណ្ដឹងជំទាស់មិនឲ្យមានការរៀបអាពាហ៍ពិពាហ៍ ដែលធ្វើឡើងដោយឪពុកម្ដាយ ឬ បុគ្គលគ្រប់រូបដែលមានផលប្រយោជន៍ ដើម្បីឲ្យមន្ត្រីមានសមត្ថកិច្ចបញ្ឈប់អាពាហ៍ពិពាហ៍នោះ និង រងចាំរហូតដល់បណ្ដឹងនោះត្រូវបានដោះស្រាយចប់។ ប្រសិនបើតុលាការបដិសេធបណ្ដឹងទាស់នោះចោល ប្ដីប្រពន្ធនោះអាចរៀបអាពាហ៍ពិពាហ៍បាន ប៉ុន្តែបើតុលាការទុកបណ្ដឹងនោះថាមិនត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ឈប់អាពាហ៍ពិពាហ៍នោះ។

ក្នុងករណីក្រោយការរៀបអាពាហ៍ពិពាហ៍ ទោះបីជាអាពាហ៍ពិពាហ៍នោះ បានប្រព្រឹត្តទៅចប់សព្វគ្រប់ តែបើអាពាហ៍ពិពាហ៍នោះធ្វើឡើងដោយផ្ទុយពីបញ្ញត្តិច្បាប់ និង មិនបានបំពេញតាមលក្ខខណ្ឌណាមួយដែលច្បាប់បានកំណត់អាពាហ៍ពិពាហ៍នោះត្រូវបានលុបចោល។

[1] មាត្រា៣ នៃច្បាប់ស្ដី ពីអាពាហ៍ពិពាហ៍ និង គ្រួសារ ឆ្នាំ ១៩៨៩

ការបកស្រាយទាំងអស់ខាងលើនេះ គឺជាលក្ខខណ្ឌចាំបាច់បំផុត សម្រាប់ការរៀបអាពាហ៍ពិពាហ៍ ឲ្យបានត្រឹមត្រូវបានតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ប្រសិនបើអាពាហ៍ពិពាហ៍ណាមិនបានគោរព និង អនុវត្តតាមគោលការណ៍ខាងលើទេនោះ អាពាហ៍ពិពាហ៍នោះ ចាប់ទុកជាអាពាហ៍ពិពាហ៍ដែលផ្ទុយទៅនឹងបញ្ញត្តិច្បាប់ដែលបានកំណត់ដែលជាហេតុនាំឲ្យមានបណ្ដឹងទាមទារឲ្យ មោឃភាព ឬ លុបចោលអាពាហ៍ពិពាហ៍នោះ។ បណ្ដឹងទាមទារឲ្យមោឃភាពអាពាហ៍ពិពាហ៍ គឺសំដៅទៅលើអាពាហ៍ពិពាហ៍ទាំងឡាយណា ដែលបង្កើតឡើងដោយភាគីគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ឬ អាពាហ៍ពិពាហ៍ដែលច្បាប់បានហាមឃាត់។ រីឯអាពាហ៍ពិពាហ៍ដែលត្រូវបានលុបចោល គឺសំដៅលើអាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយផ្ទុយពីលក្ខខណ្ឌនៃអាពាហ៍ពិពាហ៍។

## ផ្នែកទី១៖ មោឃភាពអាពាហ៍ពិពាហ៍

មោឃភាព គឺជាភាពពុំមានអានុភាពតាមផ្លូវច្បាប់ នៃសកម្មភាពគតិយុត្តដែលផ្ទុយនឹងបញ្ញត្តិអំពីនីតិវិធីនៃបណ្ដឹង។ ហើយជាទណ្ឌកម្ម ដែលប្រកាសដោយចៅក្រមលុបបំបាត់ចោលជាប្រតិសកម្មនូវ លិខិតគតយុត្តមិនបានបំពេញលក្ខណ្ឌដែលច្បាប់កំណត់ ឬសកម្មភាពណាមួយដែលផ្ទុយពីនីតិវិធីនៃច្បាប់[2]។

មោឃភាពអាពាហ៍ពិពាហ៍ គឺជាស្ថានភាពដែលគ្មានការទទួលខុសត្រូវនូវអានុភាពអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់តាំងពីដំបូង(គ្មានអាពាហ៍ពិពាហ៍)។ ដើម្បីអាចរៀបអាពាហ៍ពិពាហ៍បាន លុះត្រាតែ ភាគីមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ និងបាន ចុះបញ្ជីអាពាហ៍ពិពាហ៍[3] (សំបុត្រអាពាហ៍ពិពាហ៍) ហេតុនេះ ក្នុងករណី ភាគីពុំមានឆន្ទៈរៀបអាពាហ៍ពិពាហ៍ ឬពុំបានចុះបញ្ជីអាពាហ៍ពិពាហ៍ អាពាហ៍ពិពាហ៍នោះត្រូវចាត់ទុកជាមោឃៈ។

ទោះបីជាអាពាហ៍ពិពាហ៍នោះ បានប្រព្រឹត្តទៅចប់សព្វគ្រប់ និងមានការចុះសំបុត្រអាពាហ៍ពិពាហ៍ហើយក៏ដោយ ក៏អាពាហ៍ពិពាហ៍ត្រូវចាត់ទុកជាមោឃៈបានដែរ ប្រសិនបើវិការៈ កើតឡើងហើយវិការៈ[4]នោះ ជាមូលហេតុនាំឲ្យមានការចុះសំបុត្រអាពាហ៍ពិពាហ៍។ ដូច្នេះ បើគូភាគីដឹងថាមានលេចឡើង នូវវិការៈនោះ ពួកគេពិតជាមិនចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាជាមិនខាន។ អាពាហ៍ពិពាហ៍អាចត្រូវបានមោឃៈ ក្នុងករណីដូចខាងក្រោម៖

- ប្រសិនបើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ រវាងភាគី ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំ និង មូលហេតុផ្សេងទៀត
- ប្រសិនបើភាគី មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ឬ មិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍[5]។

[2] សន្ទានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី

[3] សំគាល់៖ ពាក្យ ចុះបញ្ជីអាពាហ៍ពិពាហ៍ សំដៅដល់ភាគីបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ជូនដំណឹងជាសាធារណៈ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ រហូតទទួលបានការចុះបញ្ជីអាពាហ៍ពិពាហ៍

[4] វិការៈ មានន័យថា ការប្រែប្រួលចាកពីប្រក្រតី

[5] មាត្រា៩៥៨ នៃក្រមរដ្ឋប្បវេណី ២០០៧

ចំណែកឯច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារវិញ បានធ្វើការញែកជាពីផ្សេងគ្នា នៃប្រភពមោឃភាពអាពាហ៍ពិពាហ៍រួមមាន មោឃភាពដាច់ខាត និង មោឃភាពមិនដាច់ខាត។

## **១.១. មោឃភាពដាច់ខាត**

មោឃភាពដាច់ខាត គឺសំដៅដល់រាល់អាពាហ៍ពិពាហ៍ទាំងឡាយណាដែលច្បាប់ហាមឃាត់តែម្តង។

### **១.១.១. ការភាន់ច្រឡំលើមនុស្ស**

ការរៀបអាពាហ៍ពិពាហ៍ដែលអាចប្រព្រឹត្តទៅបាន ដោយរលូនលុះត្រាតែអាពាហ៍ពិពាហ៍នោះកើតឡើងពីឆន្ទៈរបស់គូភាគីទាំងពីរ។ ក្នុងករណីដែលភាគីមាននឹងរៀបអាពាហ៍ពិពាហ៍ជាមួយបុគ្គលម្នាក់ ដោយសារការភាន់ច្រឡំទៅលើមនុស្សដែលខ្លួនត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយនោះ តែបែរជាខ្លួនត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយ ដូចជាការភាន់ច្រឡំនៃឈ្មោះដូចគ្នា ឬរូបរាង ឬការភាន់ច្រឡំមនុស្ស ដូចជាកូនភ្លោះដែលមានមុខមាត់ដូចគ្នា។ ការភាន់ច្រឡំលើមនុស្សដែលជាកម្មវត្ថុសំខាន់នៃអាពាហ៍ពិពាហ៍បែបនេះ ភាគីអាចស្នើសុំរំលាយកិច្ចសន្យាអាពាហ៍ពិពាហ៍នោះបាន។ ប៉ុន្តែការភាន់ច្រឡំលើមនុស្សដែរ តែការភាន់ច្រឡំនោះទៅលើអត្តចរិក ឬអាកប្បកិរិយាមនុស្សនោះ ដោយគិតថា សហព័ន្ធរបស់ខ្លួនជាមនុស្សសុភាពរាបសារ មនុស្សចិត្តល្អ តែក្រោយពេលរៀបអាពាហ៍ពិពាហ៍រួច សហព័ទ្ធនោះបានផ្លាស់ប្តូរចរិកទាំងស្រុង ភាគីដែលភាន់ច្រឡំបែបនេះ មិនអាចសុំមោឃភាពនៃអាពាហ៍ពិពាហ៍បានទេ[6]។

### **១.១.២. ការបង្ខិតបង្ខំ**

ប្រសិនបើការរៀបអាពាហ៍ពិពាហ៍ត្រូវបានបង្ខិតបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ ជាមួយភាគីម្ខាងទៀត ពីឳពុកម្តាយ ឬអាណាព្យាបាល ឬពីតតិយជនណាមួយឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយមនុស្សដែលខ្លួនមិនមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយ ឬគ្មានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយ គឺជាអំពើដែលផ្ទុយទៅនឹងស្មារតី នៃរដ្ឋធម្មនុញ្ញដែលបាបចែងថា " អាពាហ៍ពិពាហ៍ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ"[7]។ អាពាហ៍ពិពាហ៍ ដែលធ្វើឡើងដោយភាគីគ្មានសេរីភាពក្នុងការជ្រើសរើសបែបនេះ គឺបង្ហាញនូវសកម្មភាពដែលរំលោភ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលភាគីអាចដាក់ពាក្យស្នើរសុំមោឃភាព នៃអាពាហ៍ពិពាហ៍នោះបាន។ អាពាហ៍ពិពាហ៍ដែលអាចយកជាការបាន លុះត្រាតែអាពាហ៍ពិពាហ៍នោះកើតឡើងដោយភាគីទាំងសងខាងមានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា។

[6] មាត្រា៩៥៨ ចំណុច ក នៃក្រមរដ្ឋប្បវេណី ២០០៧

[7] មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ, ២៤ កញ្ញា ឆ្នាំ១៩៩៣

## ១.២. មោឃភាពមិនដាច់ខាត

មោឃភាពមិនដាច់ខាតគឺសំដៅទៅដល់ អាពាហ៍ពិពាហ៍ទាំងឡាយដែលច្បាប់បានហាមឃាត់ តែអាពាហ៍ពិពាហ៍នោះអាចកើតឡើងវិញនៅពេលដែលបំពេញគ្រប់លក្ខខណ្ឌ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍មួយមិនបានបំពេញបែបបទទៅតាមផ្លូវច្បាប់ ដូចជាការមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ឬមិនបានបំពេញបែបទជូនដំណឹងជាសាធារណៈ អាពាហ៍ពិពាហ៍មួយនឹងត្រូវបានចាប់ទុកជាមោឃៈ ឬអាចបន្តអនុវត្តក៏បាន ហៅថា មោឃភាពមិនដាច់ខាតនៃអាពាហ៍ពិពាហ៍ ដោយសារតែកំហុសមិនមានលក្ខណៈធ្ងន់ធ្ងរ។ ប៉ុន្តែបើមានវិការៈបន្តិចបន្តួចលើនីតិវិធី ដូចជាការមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ដូចនេះអានុភាពនៃអាពាហ៍ពិពាហ៍នេះ មិនត្រូវបានរារាំងដោយសារហេតុនោះឡើយ[៨]។

### ១.២.១. ភាគីមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ប្រសិនបើភាគីបានរៀបអាពាហ៍ពិពាហ៍ហើយ ដោយមិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ពីមេឃុំចៅសង្កាត់នោះទេ ភាគីអាចប្តឹងសុំមោឃភាពអាពាហ៍ពិពាហ៍បាន ឬក៏មិនស្នើសុំមោឃភាពអាពាហ៍ពិពាហ៍ក៏បាន។ ច្បាប់របស់កម្ពុជា មិនបានកំណត់ច្បាស់ថា អ្នកណាជាអ្នកមានសិទ្ធិក្នុងការប្តឹងសុំមោឃភាពអាពាហ៍ពិពាហ៍ដែលមិនបានដាក់ពាក្យសុំច្បាប់រៀបអាពាហ៍ពិពាហ៍នោះទេ។

### ១.២.២. ភាគីមិនបានជូនដំណឹងជាសាធារណៈ

ក្នុងករណីដែលគូស្រករទាំងពីរទទួលបានសិទ្ធិការអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ ដោយមន្ត្រីអត្រានុកូលដ្ឋានហើយ ប៉ុន្តែគូភាគីទាំងពីរមិនបានបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍តាមការកំណត់របស់មន្ត្រីអត្រានុកូលដ្ឋាននោះទេ គេអាចធ្វើការប្តឹងសុំមោឃភាពអាពាហ៍ពិពាហ៍នោះបាន ព្រោះគ្រាន់តែជាកំហុសបន្តិចបន្តួច។ នៅក្នុងករណីមួយទៀត ប្រសិនបើគូភាគីទាំងសងខាងបានសុំការអនុញ្ញាត ដើម្បីរៀបអាពាហ៍ពិពាហ៍ហើយ ប៉ុន្តែភាគីមិនបានជូនដំណឹងជាសាធារណៈ នូវអាពាហ៍ពិពាហ៍របស់ខ្លួន ដូចការកំណត់របស់ច្បាប់ គឺរយៈពេល ១០ថ្ងៃ នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ការខកខានប្រកាសដំណឹង នៃអាពាហ៍ពិពាហ៍នេះ អាពាហ៍ពិពាហ៍នោះអាចស្នើសុំមោឃភាពបាន ឬមិនស្នើសុំរំលាយក៏បាន ដោយសារតែជាកំហុសបន្តិចបន្តួចរបស់គូភាគី ហើយមិនមែនជាមោឃភាពដាច់ខាតដែលត្រូវលុបចោលនោះទេ។

ការដែលរំលោភនីតិវិធីតិចតួច ប្រហែលជាមិនប៉ះពាល់ដល់ភាពពេញលេញ នៃលក្ខខណ្ឌច្បាប់របស់អាពាហ៍ពិពាហ៍ ដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីនោះទេនោះទេ។ ប័ណ្ណប្រកាសត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ ដើម្បីឲ្យជនដែលមានប្រយោជន៍ក្នុងរឿងនេះដឹងឮ ហើយអាចប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះបាន

[៨] មាត្រា ៩៥៨ ចំណុច ខ នៃក្រមរដ្ឋប្បវេណី ២០០៧

ប្រសិនបើមានការមិនយល់ព្រមស្រប និងអាពាហ៍ពិពាហ៍នោះ។ ផុតរយៈពេល ១០ថ្ងៃនេះ អាពាហ៍ពិពាហ៍អាចធ្វើទៅបានបើគ្មានការប្តឹងជំទាស់[9]។

ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីមិនបានបញ្ជាក់ឲ្យច្បាស់លាស់ នូវផលប៉ះពាល់នៃការខកខានមិនបានបំពេញតាមលក្ខខណ្ឌតម្រូវ នៃនីតិវិធីដែលបានកើតឡើងខាងលើនេះទេ។ ប៉ុន្តែអាពាហ៍ពិពាហ៍នោះទំនង នឹងត្រូវចាប់ទុកថាត្រឹមត្រូវតាមលក្ខណៈច្បាប់។ ការធ្វើបែបនេះ គឺដើម្បីជំរុញដល់អាពាហ៍ពិពាហ៍ និងធ្វើឲ្យសហព័ទ្ធទាំងសងខាងមានទំនុកចិត្តថា អាពាហ៍ពិពាហ៍របស់ខ្លួនមានតម្លៃតាមផ្លូវច្បាប់។

**១.២.៣. ភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍**

ក្រោយពេលរៀបអាពាហ៍ពិពាហ៍ហើយ នឹងចាប់ទុកថាអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមលក្ខណៈច្បាប់ លុះត្រាតែបុរស និងនារី បានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ២រូប ជានីតិជន និងជាមនុស្សគួរឲ្យទុកចិត្តបាន ដែលបានដឹងឮផ្ទាល់ពីសាមីខ្លួន ប្តីប្រពន្ធ នោះនិងធ្លាប់រស់នៅក្នុងភូមិឃុំ ឬសង្កាត់ជាមួយគ្នា នាំមកបញ្ជាក់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន[10]។ ក្នុងករណីដែលភាគីមិនបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននោះទេ គេអាចស្នើសុំមោឃភាពអាពាហ៍ពិពាហ៍បាន។

**១.២.៤. ភាគីមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍**

នៅពេលដែលសហព័ទ្ធទាំងពីរបានចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ រួចហើយនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានក្តី ប៉ុន្តែបើពួកគេមិនបាន ចុះបញ្ជីអាពាហ៍ពិពាហ៍ នៅក្នុងសៀវភៅអាពាហ៍ពិពាហ៍របស់មន្ត្រីអត្រានុកូលដ្ឋាននោះទេ គេអាចស្នើសុំប្តឹងមោឃភាពអាពាហ៍ពិពាហ៍នោះបាន។

សរុបមក ទោះបីជាច្បាប់បានចែងពីមូលហេតុនៃការមោឃភាពនេះក៏ដោយ តែរាល់មូលហេតុនៃចំណុចមោឃភាពមិនដាច់ខាតនេះ នៅក្នុងករណីជាក់ស្តែង គឺស្ទើរតែគ្មានអានុភាពក្នុងការរារាំងអាពាហ៍ពិពាហ៍។

## ផ្នែកទី២៖ ការលុបចោលអាពាហ៍ពិពាហ៍

ការលុបចោលអាពាហ៍ពិពាហ៍ គឺជាការលុបចោលអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវ មិនស្របច្បាប់ ឬអាពាហ៍ពិពាហ៍ដែលផ្ទុយពីលក្ខន្តិកៈនៃការរៀបអាពាហ៍ពិពាហ៍។ ការលុបចោលអាពាហ៍ពិពាហ៍ត្រូវយោងទៅតាមបញ្ញត្តិដែលច្បាប់បានចែង ព្រោះជាការធ្វើឲ្យប៉ះពាល់យ៉ាងធំធេងទាំងផ្លូវកាយ ផ្លូវចិត្តនិងកិត្តិយសដល់ គូភាគីឪពុកម្តាយ និង ញាតិសន្តានទាំងសងខាងទៀតផង។ ប៉ុន្តែការលុបចោលអាពាហ៍ពិពាហ៍នេះក៏មានសារៈសំខាន់ដែរ ប្រសិនអាពាហ៍ពិពាហ៍នោះធ្វើឲ្យប៉ះពាល់យ៉ាងធំធេង ក្នុងករណីនេះភាគីនីមួយៗ ឪពុកម្តាយ ញាតិស

---

[9] មាត្រា១៣ នៃច្បាប់ស្តី ពីអាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩

[10] មាត្រា៣០ នៃអនុក្រឹត្យស្តីពី អត្រានុកូលដ្ឋាន ២០០០

ន្តានរបស់ជននោះ ឬ តំណាងអយ្យការអាចទាមទារទៅតុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដោយមូលហេតុត្រឹមត្រូវ ។

មូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍បានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មានដូចជា មិនគោរពលក្ខខណ្ឌអាយុរៀបការ ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងពេលហាមឃាត់ ទ្វេពន្ធភាព ការគោរពវិធវភាព[11](តាមក្រមថ្មី១២០ថ្ងៃ) ការបំពានលក្ខខណ្ឌហាមឃាត់ចំពោះអាពាហ៍ពិពាហ៍រវាងញាតិលោហិត ឬរវាងញាតិពន្ធ ការឆបោក ឬគំរាមកំហែង។

## ២.១. អាពាហ៍ពិពាហ៍ដែលភាគីមិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍

ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារបានបញ្ញត្តិថា បុរសចាប់ពីអាយុ ២០ឆ្នាំ ឡើងចំណែកនារីវិញត្រូវមានអាយុចាប់ពី ១៨ឆ្នាំ ឡើងទៅទើបអាចរៀបអាពាហ៍ពិពាហ៍បាន[12]។ ដោយឡែកក្រមរដ្ឋប្បវេណីបច្ចុប្បន្ន បានកំណត់យក អាយុ១៨ឆ្នាំ ដែលជាអាយុដល់នីតិភាពមកជាអាយុអប្បបរមាដែលសមរម្យអាចរៀបអាពាហ៍ពិពាហ៍បាន ដូចនេះមានន័យថា បុរស និង នារីដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ[13] ចំពោះអាពាហ៍ពិពាហ៍ដែលកើតឡើងដោយភាគីនៃអាពាហ៍ពិពាហ៍មិនទាន់គ្រប់អាយុរៀបអាពាហ៍ បុគ្គលដែលមានផលប្រយោជន៍ អាចប្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែ ប្រសិនបើភាគីនៃអាពាហ៍ពិពាហ៍បានគ្រប់អាយុរៀបអាពាហ៍ពិពាហ៍ហើយ សិទ្ធិទាមទារលុបចោលនោះ នឹងត្រូវរលត់។ ក្នុងករណីនេះ ទោះបីជាជន មិនទាន់គ្រប់អាយុរៀបអាពាហ៍ពិពាហ៍ បានដល់អាយុរៀបអាពាហ៍ពិពាហ៍ហើយក៏ដោយ ជននោះក៏អាចទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបានដែរ នៅក្នុងអំឡុងពេល ៣ខែ ចាប់ពីពេលដែលជននោះបានគ្រប់អាយុ[14]។

នៅក្នុងករណីពិសេស បើបុរសដែលត្រូវរៀបអាពាហ៍ពិពាហ៍មានអាយុមិនទាន់ដល់ ២០ឆ្នាំ និង នារីដែលមានអាយុមិនទាន់ដល់ ១៨ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បានប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្ដាយ ឬ អ្នកអាណាព្យាបាល[15]។

ការកំណត់ពីអាយុ នៃបុគ្គលក្នុងការរៀបអាពាហ៍ពិពាហ៍ត្រូវបានកំណត់យ៉ាងច្បាស់លាស់ដែលមិនឲ្យបុគ្គលណាមកបំពានលើការកំណត់នេះឡើយ ដោយលើកលែងតែ ករណីពិសេសដែលបានបកស្រាយនៅខាងលើ។ ការកំណត់ពីអាយុនៃភាគីរៀបអាពាហ៍ពិពាហ៍ គឺដើម្បីឲ្យភាគីទាំងសងខាងមានការទទួលខុសត្រូវចំពោះ

[11] វិធវភាព មានន័យថា ភាពទំនេរ , ភាពមេម៉ាយ

[12] មាត្រា៥ នៃច្បាប់ស្តី ពីអាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩

[13] មាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណី ២០០៧

[14] មាត្រា៩៦១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[15] មាត្រា៥ នៃច្បាប់ស្តី ពីអាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩

គ្រួសាររបស់ខ្លួន មានកាយសម្បទាគ្រប់គ្រាន់សំរាប់ការរកស៊ីចិញ្ចឹមជីវិត មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបើថែរក្សាកូន បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍។

## ២.២. អាពាហ៍ពិពាហ៍ធ្វើនៅក្នុងអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍

កាលពីឆ្នាំ ១៩៨៩ ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ បានបញ្ញត្តិថា ក្រោយពីអាពាហ៍ពិពាហ៍រលាយដោយមូលហេតុប្តីស្លាប់ មោឃភាពនៃអាពាហ៍ពិពាហ៍ ឬ លែងលះគ្នានារីអាចរៀបអាពាហ៍ពិពាហ៍ថ្មីមួយទៀតបាន ប៉ុន្តែត្រូវស្ថិតនៅក្នុងវិធវភាព(ភាពមេម៉ាយ) ចំនួន ៣០០ថ្ងៃ គិតចាប់ពីថ្ងៃដែលប្តីស្លាប់ ឬ ពីថ្ងៃប្រកាសសាលក្រមដែលសម្រេចពីមោឃភាពនៃអាពាហ៍ពិពាហ៍ ឬ ពីថ្ងៃប្រកាសសាលក្រមស្ថាពរនៃការលែងលះ[16]។ ចំណែកឯក្រមរដ្ឋប្បវេណីបច្ចុប្បន្នកែប្រែអំពី អំឡុងពេលហាមឃាត់គឺ ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍ម្តងទៀតដោយមិនទាន់ផុតរយៈពេល ១២០ថ្ងៃ ក្រោយពេលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយអាពាហ៍ពិពាហ៍ថ្មីនេះនឹងត្រូវបានលុបចោល[17] ដូចនេះហើយស្ត្រីអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានលុះត្រាតែរយៈពេល ១២០ថ្ងៃ បានកន្លងផុត។ ចំពោះករណីដែលនារីមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោលហើយបានសម្រាលកូន ឬ មានការបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត ការលុបចោលនឹងមិនមានអានុភាពទៅលើអាពាហ៍ពិពាហ៍ថ្មីទេ[18]។

ការកំណត់មិនឲ្យ ស្ត្រីរៀបអាពាហ៍ពិពាហ៍ថ្មីនៅក្នុងអំឡុងពេលហាមឃាត់ គឺជាអំឡុងពេលដែលច្បាប់បានកម្រិតសំរាប់ស្ត្រី ដើម្បីជៀសវាងពីបញ្ហាជាមួយគ្នាក្នុងការកំណត់អំពីបិតុភាព។ ចំណែកឯបុរសវិញ អាចរៀបការជាថ្មីម្តងទៀតនៅពេលណាក៏បានក្រោយពេលអាពាហ៍ពិពាហ៍មុនត្រូវបានបញ្ចប់។

## ២.៣. ទ្វេពន្ធភាព

អាពាហ៍ពិពាហ៍ត្រូវធ្វើឡើងដោយគោរពលក្ខខណ្ឌដែលបានចែងនៅក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយ ប្រពន្ធ[19]។ ដោយសារការ អនុម័តយករបបឯកពន្ធភាព បុរសត្រូវហាមឃាត់មិនឲ្យមានអាពាហ៍ពិពាហ៍លើសពីមួយ ចំណែកឯនារីវិញក៏មិនត្រូវរៀបអាពាហ៍ពិពាហ៍លើសពីមួយផងដែរ។ ចំណងអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ ឯកពន្ធភាពស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ដោយមានការចុះបញ្ជីអាពាហ៍ពិពាហ៍ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របតាមក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ[20] ដែលត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ដូចនេះបុគ្គលដែលមានសហព័ន្ធ

---

[16] មាត្រា៩ នៃច្បាប់ស្តី ពីអាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩

[17] មាត្រា៩៦២ នៃក្រមរដ្ឋប្បវេណី ២០០៧

[18] មាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី ២០០៧

[19] មាត្រា៤៥ នៃរដ្ឋធម្មនុញ្ញ, ២៤ កញ្ញា ឆ្នាំ១៩៩៣

[20] មាត្រា២ នៃច្បាប់ស្តីពី ឯកពន្ធភាព ២០០៦

ហើយពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានទេ[21]។ ក្នុងករណីដែលបុរស ឬ នារីដែលបានរៀបអាពាហ៍ពិពាហ៍រួច ហើយ តែគាត់បានទៅចុះបញ្ជីអាពាហ៍ពិពាហ៍ថ្មីមួយទៀត ដោយអាពាហ៍ពិពាហ៍ចាស់មិនទាន់រលត់ ក្នុងករណីនេះ បុគ្គលនោះត្រូវចាត់ទុកថាមានពិរុទ្ធក្នុងបទទ្វេពន្ធភាព ហើយអ្នកដែលសមគំនិតនៅក្នុងរឿងនេះ ក៏ត្រូវមានទោសដូចគ្នាដែរ[22]។ ប៉ុន្តែ អាពាហ៍ពិពាហ៍ក្រោយក៏អាចពេញលក្ខណៈច្បាប់ផងដែរ ប្រសិនបើអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយមុនមានការប្តឹងសុំលុបចោលអាពាហ៍ពិពាហ៍[23]។

ចំពោះអាពាហ៍ពិពាហ៍ដែលជាប់ក្នុងបទទ្វេពន្ធភាព បុគ្គលដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិនេះ ត្រូវជាប់ទោសព្រហ្មទណ្ឌដាក់ពន្ធនាគារពី ៦ ខែ ដល់ ១ ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់ ១.០០០.០០០ (មួយលាន) រៀល ឬ ផ្តន្ទាទោសណាមួយនៃទោសទាំងពីរ[24]។

## ២.៤. អាពាហ៍ពិពាហ៍រវាងញាតិលោហិត

អាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយភាគីបុរស និង នារី ដែលជាប់ញាតិលោហិតផ្ទាល់ ឬ សាខាញាតិលោហិតក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ (បី) ផង អាពាហ៍ពិពាហ៍នោះត្រូវបានហាមឃាត់[25] ដូចនេះ អាពាហ៍ពិពាហ៍ដែលធ្វើឡើងរវាង ឪពុក ឬ ម្តាយ និង កូន បងប្អូនបង្កើត និង បងប្អូនបង្កើត មីង ឬ ពូបង្កើត និង ក្មួយ អាពាហ៍ពិពាហ៍នោះ នឹងត្រូវលុបចោល[26]។

ការហាមឃាត់រវាងបុគ្គលដែលជាប់ចំណងញាតិលោហិត ឬ ញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬ សាច់ចិញ្ចឹមក្តី[27] គឺត្រូវបានហាមឃាត់ជាដាច់ខាត ចំពោះអាពាហ៍ពិពាហ៍រវាងគ្នានិងគ្នា ដោយសារមូលហេតុនៃសុជាតិវិទ្យា និង មូលហេតុសីលធម៌សង្គម។ បើយោងទៅតាមសេចក្តីកំណត់នៃក្រមរដ្ឋប្បវេណី គន្លឹះទី៧ បានបកស្រាយពីមូលហេតុនៃសុជាតិវិទ្យា គឺការរៀបអាពាហ៍ពិពាហ៍រវាងញាតិថ្នាក់ជិត ងាយនឹងបណ្តាលឲ្យកូនដែលកើតមក មានអាការៈខ្សោយ ប្រឈប់មុខទៅនឹងជំងឺច្រើន ហើយលទ្ធភាពនៃពិការភាពចំពោះកូនដែលកើតមកកើនឡើងខ្ពស់។ ក៏ប៉ុន្តែ ការហាមឃាត់នូវអាពាហ៍ពិពាហ៍ចំពោះញាតិថ្នាក់ជិតបែបនេះ បានបណ្តាលមកពីហេតុផលសីលធម៌សង្គមច្រើនជាងហេតុផលសុជាតិវិទ្យា។ ចំពោះមូលហេតុសីលធម៌វិញ ក៏ជាបញ្ហាមួយធំផងដែរ ព្រោះវាបានផ្ទុយពីសីលធម៌សង្គម ហើយសង្គមក៏មិនទទួលស្គាល់ចំពោះអាពាហ៍ពិពាហ៍បែបនេះដូចគ្នា។ ជាការពិតណាស់ការរៀបអាពាហ៍ពិពាហ៍រវាង

[21] មាត្រា៩៤៩ នៃក្រមរដ្ឋប្បវេណី ២០០៧

[22] មាត្រា៤ នៃច្បាប់ស្តីពី ឯកពន្ធភាព ២០០៦

[23] មាត្រា៩៦០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[24] មាត្រា៩ នៃច្បាប់ស្តីពី ឯកពន្ធភាព មាត្រា៩ នៃ

[25] មាត្រា៩៥១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[26] មាត្រា៩៦០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

[27] មាត្រា៧ នៃច្បាប់ស្តី ពីអាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩

ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម និង កូនសុំក៏ត្រូវបានហាមឃាត់ផងដែរ។ ទោះបីជាទំនាក់ទំនងញាតិរវាងកូនសុំ និង ឪពុកម្តាយបង្កើតបានកាត់ផ្តាច់ដោយសារការបង្កើតសុំកូនពេញលេញក៏ដោយ ក៏ទំនាក់ទំនងលោហិតតាមធម្មជាតិមិនរលត់ដែរ ដូចនេះការហាមឃាត់រវាងថ្នាក់ជិតនៅទេមានដដែរ។

## ២.៥. អាពាហ៍ពិពាហ៍រវាងញាតិពន្ធ

**ញាតិពន្ធ** សំដៅដល់ ចំណងគតិយុត្តរវាងសហព័ទ្ធម្ខាង និងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត ឬ ហៅថា សាច់ថ្លៃ[28]។

**ឧទាហរណ៍៖** ឪពុកម្តាយក្មេក និងកូនប្រសា បងថ្លៃ ប្អូនថ្លៃ (ខាងប្តី ឬខាងប្រពន្ធ)។

**ញាតិពន្ធខ្សែផ្ទាល់** សំដៅដល់ ញាតិលោហិតផ្ទាល់ខាងសាច់ថ្លៃ ដែលកើតតពីមួយទៅមួយតាមសំដាប់ ដូចជា ជីដូនជីតាក្មេក ឪពុកម្តាយក្មេក កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត[29]។

បុរស និង ស្ត្រី ដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នា ហើយអាពាហ៍ពិពាហ៍នោះមានជាប់ចំណងញាតិពន្ធក្នុងខ្សែផ្ទាល់ និង រវាងសាខាញាតពន្ធ នៅក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី៣ផង អាពាហ៍ពិពាហ៍នោះពុំអាចធ្វើបានឡើយ[30]។ ការហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធនៃខ្សែផ្ទាល់ និង រវាងជនដែលធ្លាប់ជាញាតិពន្ធនៃខ្សែផ្ទាល់[31]។ ដោយសារញាតិលោហិត នៃខ្សែផ្ទាល់របស់សហព័ន្ធរបស់សហព័ន្ធមានទំនាក់ទំនងប្រហាក់ប្រហែល និង ញាតិលោហិតខ្សែផ្ទាល់របស់ខ្លួនផ្ទាល់ ដែលស្រដៀងគ្នាទៅនឹងទំនាក់ទំនងឪពុកម្តាយ និង កូន ដូច្នេះ តាមសីលធម៌សង្គម ក៏អាពាហ៍ពិពាហ៍បែបនេះមិនមែនជាការគួរដែរ។

ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ទាំងអស់ហើយទោះបីទំនាក់ទំនងញាតិពន្ធខ្សែផ្ទាល់ត្រូវបានបញ្ចប់ហើយក៏ដោយមានដូចជា៖

- រវាងឪពុកម្តាយក្មេក និង កូនប្រសា
- រវាងជីដូនជីតាក្មេក និង ចៅប្រសា
- រវាងជីដូនជីតាទួតក្មេក និង ចៅទួតប្រសា
- រវាងជីលួតក្មេក និង ចៅលួតប្រសា
- រវាងជីលាក្មេក និង ចៅលាប្រសា
- រវាងអតីតម្តាយក្មេក និង អតីតកូនប្រសា
- រវាងអតីតជីដូនជីតាក្មេក និង អតីតចៅប្រសា

---

28 សន្ធានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី

29 សន្ធានុក្រមពាក្យច្បាប់ រដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី

30 មាត្រា៩៥២ នៃក្រមរដ្ឋប្បវេណី ២០០៧

31 មាត្រា៩៥២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

- រវាងអតីតជីដូនជីតាទួតក្មេក និង អតីតចៅទួតប្រសា
- រវាងអតីតជីលួតក្មេក និង អតីតចៅលួតប្រសា
- រវាងអតីតជីលាក្មេក និង អតីតចៅលាប្រសា

ការហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍រវាងសាខាញាតិនៅក្នុង ៣ (បី) ថ្នាក់ រាប់ទាំងបីថ្នាក់ទី៣ផង មានដូចជា៖

- រវាងបងថ្លៃប្អូនថ្លៃ (សាខាញាតិពន្ធថ្នាក់ទី២)
- រវាងអតីតបងថ្លៃ និង អតីតប្អូនថ្លៃ
- រវាងពូ ឬ មីងក្មេក ជាមួយក្មួយប្រសា (សាខាញាតិថ្នាក់ទី៣)
- រវាងអតីតពូមីងក្មេក ជាមួយអតីតក្មួយប្រសារ
- រវាងបងប្អូនបង្កើតរបស់ប្ដីជាមួយបងប្អូនបង្កើតរបស់ប្រពន្ធ
- រវាងអតីតបងប្អូនបង្កើតរបស់ប្ដីជាមួយអតីតបងប្អូនបង្កើតរបស់ប្រពន្ធ

អាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយរវាងសាខាញាតិពន្ធ នៅក្នុង ៣ (បី) ថ្នាក់ រាប់ទាំងថ្នាក់ទី៣ផង ក៏ច្បាប់ត្រូវបានហាមឃាត់ផងដែរ[32] ដោយសារតែនៅក្នុងសង្គមកម្ពុជា សាខាញាតិពន្ធនេះមាននិន្នាការបង្កើតទំនាក់ទំនងញាតិជារួមដែលមានលក្ខណៈជិតស្និទ្ធស្រដៀង គ្នាទៅនឹងញាតិលោហិតខ្សែផ្ទាល់ និង សាខាញាតិលោហិតដែរ។ ក្នុងករណីពិសេស ប្រសិនបើសហព័ន្ធណាមួយស្លាប់ សហព័ន្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយសាខាងញាតិប្រពន្ធថ្នាក់ទី២ ឬថ្នាក់ទី៣ បាន[33]។ ដោយសារតែតាមទំនៀមទំលាប់ក្នុងប្រទេសកម្ពុជា មានករណីអាពាហ៍ពិពាហ៍ជាមួយបងប្អូនថ្លៃ ដូចជាករណីដែលប្ដីបានទទួលមរណភាពទៅ ហើយប្រពន្ធបានទៅរៀបអាពាហ៍ពិពាហ៍ជាមួយបង ឬ ប្អូនប្រុសដែលនៅលីវរបស់សពប្ដី ឬ ក្នុងករណីដែលប្រពន្ធទទួលមរណភាពហើយប្អូនស្រី ឬ បងស្រីរបស់សពប្រពន្ធទៅរៀបអាពាហ៍ពិពាហ៍ជាមួយប្ដី នៅក្នុងគោលបំណងដើម្បីជួយមើលថែទាំកូនរបស់បុគ្គលដែលទទួលមរណភាពនោះ។

## ២.៦. អាពាហ៍ពិពាហ៍ដោយការឆបោក

អាពាហ៍ពិពាហ៍រវាងបុរស និង ស្ត្រី ដោយការឆបោកលើភាគីម្ខាងទៀត ឬតតិយជនដោយមធ្យោបាយធ្វើឲ្យភាគីម្ខាងទៀតទៅក្នុងការភាន់ច្រឡំ ភាគីដែលបានបង្ហាញឆន្ទៈ ដោយការឆបោកនោះ អាចស្នើរសុំទៅតុលាការ ដើម្បីលុបចោលអាពាហ៍ពិពាហ៍[34]។ ការឆបោក អាចជាករណីដូចជាអាពាហ៍ពិពាហ៍ដែលត្រូវកើតឡើង

[32] មាត្រា៩៥២ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[33] មាត្រា៨ នៃច្បាប់ស្ដី ពីអាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩

[34] មាត្រា៩៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

ដោយសារមធ្យោបាយដែលត្រូវបានប្រើប្រាស់ដែលមានលក្ខណៈឆបោក ពាក់ព័ន្ធទៅនឹងសមត្ថភាពផ្លូវភេទ ឬ ចំណុចសំខាន់ៗផ្សេងៗទៀតជាសត្យានុម័ត ឬ ជាអត្តនាម័ត ឬ ដោយពាក្យសម្ដី។

សិទ្ធិនៃការប្ដឹងស្នើសុំឲ្យលុបចោលអាពាហ៍ពិពាហ៍នោះ មានរយៈពេល ៣ខែ ចាប់តាំងក្រោយថ្ងៃដែលភាគីរកឃើញការឆបោកនោះ។ ប្រសិនបើផុតរយៈពេល ៣ខែ នោះ ភាគីមិនបានស្នើសុំតុលាការឲ្យរំលាយអាពាហ៍ពិពាហ៍ ឬ មិនបានប្ដឹងលុបចោលអាពាហ៍ពិពាហ៍នោះ ឬ ក្នុងអំឡុងពេលដែលរកឃើញអំពីការឆបោកនោះ ភាគីបានសុខចិត្តទទួលស្គាល់អាពាហ៍ពិពាហ៍នោះ សិទ្ធិក្នុងការលុបចោលអាពាហ៍ពិពាហ៍ របស់ភាគីនោះនឹងត្រូវបានរលត់[35]។

### ២.៧. អាពាហ៍ពិពាហ៍ដោយការគំរាមកំហែង

បុរស និង ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍គ្នានឹងគ្នាហើយ តែអាពាហ៍ពិពាហ៍នោះ កើតឡើងដោយការគំរាមកំហែងភាគីម្ខាងទៀត ឬ របស់តតិយជន តាមគ្រប់មធ្យោបាយធ្វើឲ្យភាគីម្ខាងទៀត សុខចិត្តទទួលយកការរៀបអាពាហ៍ពិពាហ៍ដោយខុសពីឆន្ទៈរបស់ខ្លួន ភាគីដែលបានបង្ហាញឆន្ទៈដោយការគំរាមកំហែងនេះ អាចធ្វើការស្នើសុំទៅតុលាការដើម្បីលុបចោលអាពាហ៍ពិពាហ៍នោះ[36]។

សិទ្ធិស្នើសុំលុបចោលអាពាហ៍ពិពាហ៍នេះ មានរយៈពេល ៣ខែ ចាប់តាំងក្រោយថ្ងៃដែលភាគីបានគេចចេញពីការគំរាមកំហែងនេះ។ បើផុតរយៈពេល ៣ខែនោះភាគីមិនបានស្នើសុំទៅតុលាការដើម្បីរំលាយអាពាហ៍ពិពាហ៍ ឬ ក្នុងអំឡុងពេលដែលបានគេចចេញពីការគំរាមកំហែងនោះ ភាគីបានធ្វើសច្ចានុម័ត ភាគីនោះនឹងរលត់សិទ្ធិ ដើម្បីប្ដឹងលុបចោលអាពាហ៍ពិពាហ៍។

**សម្គាល់៖** រយៈពេលនៃការប្ដឹងសុំលុបចោលអាពាហ៍ពិពាហ៍ ដែលកើតឡើងដោយការឆបោក ឬ គំរាមកំហែង មានរយៈពេលដូចគ្នា។

## ផ្នែកទី៣៖ អ្នកមានសិទ្ធិទាមទារឲ្យមោឃភាព និង លុបចោលអាពាហ៍ពិពាហ៍

### ៣.១. អ្នកមានសិទ្ធិទាមទារឲ្យមោឃភាពអាពាហ៍ពិពាហ៍

អ្នកដែលមានសិទ្ធិទាមទារឲ្យមោឃភាពអាពាហ៍ពិពាហ៍ មានតែសហព័ទ្ធ រដ្ឋអាជ្ញា និង ជនដែលមានប្រយោជន៍ស្របច្បាប់ក្នុងការប្ដឹងសុំមោឃភាព នៃអាពាហ៍ពិពាហ៍ទេ ទើបអាចដាក់ពាក្យប្ដឹងសុំមោឃភាព នៃអាពាហ៍ពិពាហ៍ទៅតុលាការប្រជាជនបាន ដោយយោងតាម មាត្រា ២៦ នៃ ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩។ ចំណែកឯក្រមរដ្ឋប្បវេណីបច្ចុប្បន្ន ពុំបានបញ្ញត្តិ អំពីអ្នកដែលមានសិទ្ធិធ្វើបណ្ដឹងទាមទារឲ្យបញ្ជាក់ អំពីមោឃភាពនោះទេ តែយើងអាចបកស្រាយបាន ជនណាក៏អាចធ្វើបានដែរ ប៉ុន្តែដើម្បីធ្វើបណ្ដឹងបញ្ជាក់អំពីមោឃ

[35] មាត្រា៩៦៣ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ២០០៧

[36] មាត្រា៩៥២ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

ភាព លុះត្រាតែ អ្នកដែលមានផលប្រយោជន៍ នៃការធ្វើបណ្ដឹង ហេតុនេះ ជនដែលមានផលប្រយោជន៍ នៃបណ្ដឹង ប៉ុណ្ណោះដែលអាចធ្វើបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាព[37]។

**៣.១.១. សហព័ទ្ធ**

មានតែសហព័ទ្ធរបស់ ភាគីដែលរៀបអាពាហ៍ពិពាហ៍ ដែលមានសិទ្ធិក្នុងការធ្វើ បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាព គឺនៅពេលដែលភាគីបានដឹងពីភាពមិនប្រក្រតីរបស់អាពាហ៍ពិពាហ៍របស់ខ្លួនដែលកើតឡើង ដូចជា ករណី ភាន់ច្រឡំលើមនុស្ស ការបង្ខំ គ្មានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍ និង មានមូលហេតុផ្សេងៗទៀត។

អាពាហ៍ពិពាហ៍ដែលកើតឡើងដោយការភាន់ច្រឡំលើមនុស្ស ឬ ភាន់ច្រឡំអំពីអត្តសញ្ញាណរបស់មនុស្ស គឺ មានតែភាគីដែលរៀបអាពាហ៍ពិពាហ៍ផ្ទាល់ ដែលមានសិទ្ធិក្នុងការទាមទារឲ្យមោឃភាពអាពាហ៍ពិពាហ៍នោះ នៅក្រោយពេលដែលខ្លួនបានដឹង អំពីការភាន់ច្រឡំនោះ។ តែបើក្នុងករណីដែលជនដែលបានដាក់ពាក្យបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោភាពនោះបានស្លាប់ សិទ្ធិវន្តអាចប្ដឹងជំនួសបាន[38]។

**៣.១.២. តំណាងអយ្យការ**

ក្នុងករណីដែលសហព័ទ្ធណាមួយដាក់ពាក្យបណ្ដឹងទៅតុលាការដើម្បីទាមទារឲ្យបញ្ជាក់អំពីមោឃភាព អាពាហ៍ពិពាហ៍ ដោយសារតែអាពាហ៍ពិពាហ៍នោះបានបំពានលក្ខខណ្ឌណាមួយនៃអាពាហ៍ពិពាហ៍ ការបំពាននោះមានផលប៉ះពាល់ទៅដល់ផលប្រយោជន៍សាធារណៈ ដូចនេះហើយតុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការ ដើម្បីការពារផលប្រយោជន៍សាធារណៈ ដូច្នេះហើយតំណាងអយ្យការមានសិទ្ធិចូលរួមក្នុងនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល និង បញ្ចេញយោបល់នៅក្នុងនីតិវិធីនៃបណ្ដឹង ដោយយល់ថាចាំបាច់ក្នុងការពារផលប្រយោជន៍សាធារណៈ ប៉ុន្តែទោះបីតុលាការមិនបានជូនដំណឹងទៅតំណាងអយ្យការ ក៏តំណាងអយ្យការអាចចូលរួមក្នុងនីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណី និង បញ្ចេញយោបល់បានដែរ ប្រសិនបើយល់ឃើញថា ចាំបាច់ក្នុងការការពារផលប្រយោជន៍សាធារណៈ។

**៣.១.៣. ជនដែលមានផលប្រយោជន៍ពាក់ព័ន្ធ**

ជនដែលមានផលប្រយោជន៍ គឺសំដៅទៅលើបុគ្គលគ្រប់រូបដែលមានផលប្រយោជន៍ នៅក្នុងការធ្វើបណ្ដឹងទាមទារបញ្ជាក់ពីមោឃភាព នៃអាពាហ៍ពិពាហ៍។ ជនដែលមានផលប្រយោជន៍ អាចជា ឪពុកម្ដាយ សាមីខ្លួនផ្ទាល់ បងប្អូនបង្កើត ញាតិលោហិត សាខាញាតិ ជនដែលមានប្រយោជន៍ផ្សេងៗទៀត។ សាច់ញាតិរបស់ភាគី ឬជនដែលមានប្រយោជន៍ក្នុងរឿងនេះក្ដី អាចប្ដឹងជំទាស់មិនឲ្យរៀបអាពាហ៍ពិពាហ៍បាន ក្នុងរយៈពេល ១០ថ្ងៃ

[37] មាត្រា៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[38] មាត្រា២៦ កថាខណ្ឌទី២ នៃច្បាប់ស្ដី ពីអាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩

គិតពីថ្ងៃដែលបិទផ្សាយជាសាធារណៈ[39]។ អ្នកប្តឹងទាស់ត្រូវចុះហត្ថលេខាលើពាក្យរបស់ខ្លួនដោយផ្ទាល់ និង ចង្អុលបង្ហាញឲ្យបានច្បាស់លាស់អំពីចំណុចដែលខ្លួនប្តឹងជំទាស់ ហើយបញ្ជូនទៅមេឃុំ ឬ ចៅសង្កាត់ ឬ ទៅកាន់តុលាការ ដែលនៅលំនៅដ្ឋាននៃអនាគតប្រពន្ធ។

## ៣.២. អ្នកមានសិទ្ធិទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍

អំពីបុគ្គលដែលមានសិទ្ធិទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ក៏បានកំណត់ផងដែរថា ការទាមទារត្រូវធ្វើឡើងដោយការដាក់ពាក្យបណ្តឹងទៅតុលាការ ដោយសារតែអានុភាព នៃការលុបចោលអាពាហ៍ពិពាហ៍ចាំបាច់ត្រូវធ្វើការកំណត់ជាស្ថាពរឲ្យមានលក្ខណៈជាឯកសណ្ឋាន។ អ្នកមានសិទ្ធិប្តឹងទាមទារឲ្យលុបចោលនូវអាពាហ៍ពិពាហ៍ដែលមិនត្រឹមត្រូវទាំងនោះ មានដូចជា ភាគីណាម្ខាងនៃអាពាហ៍ពិពាហ៍ ញាតិរបស់ជននោះ ឬ តំណាងអយ្យការ ចំពោះករណី ទ្វេពន្ធភាព ឬ ការបំពានអំឡុងពេលហាមឃាត់មិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីវិញ សហព័ន្ធរបស់ភាគី ឬ សហព័ន្ធនៃអាពាហ៍ពិពាហ៍មុន ក៏អាចទាមទារឲ្យលុបចោលបានដែរ។ អ្នកមានសិទ្ធិទាមទារឲ្យលុបចោលត្រូវបានប្រែប្រួលទៅតាមមូលហេតុនៃការលុបចោល ដូចនេះហើយ អ្នកដែលមានសិទ្ធិត្រូវធ្វើ ការលុបចោលតាមរយៈបណ្តឹងទាមទារឲ្យលុបចោល។

### ៣.២.១. សហព័ន្ធ

មានតែភាគីដែលរៀបអាពាហ៍ពិពាហ៍ដោយផ្ទាល់ទេ ទើបមានសិទ្ធិដាក់ពាក្យបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន។ ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ មានសិទ្ធិទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍នៅពេលដែលខ្លួនបានដឹង អំពីភាពមិនប្រក្រតីចំពោះអាពាហ៍ពិពាហ៍របស់ខ្លួន ដែលជាលក្ខខណ្ឌចាំបាច់ក្នុងការហាមឃាត់។

បុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម អាចទាមទារទៅតុលាការឲ្យលុបចោលអាពាហ៍ពិពាហ៍នោះបាន[40]។ ដើម្បីការពារបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម ពីសំណាក់ភាគីម្ខាងទៀត គឺមានតែភាគីនៃអាពាហ៍ពិពាហ៍ តែប៉ុណ្ណោះដែលត្រូវបានប្រគល់នូវសិទ្ធិលុបចោលអាពាហ៍ពិពាហ៍នោះ។ ភាគីម្ខាងនៃការលុបចោលគឺ ជាភាគីម្ខាងទៀតនៃអាពាហ៍ពិពាហ៍ ដោយរាប់បញ្ចូលទាំងករណីឆបោក ឬ ការគំរាមដែលត្រូវបានធ្វើឡើងដោយតតិយជនផងដែរ។

### ៣.២.២. ញាតិសណ្តានរបស់ភាគី

ញាតិសណ្តានរបស់ភាគីនីមួយៗ ក៏អាចដាក់ពាក្យបណ្តឹងឲ្យលុបចោលអាពាហ៍ពិពាហ៍បានដែរ ប្រសិនបើបានដឹងអំពីភាពមិនប្រក្រតីរបស់អាពាហ៍ពិពាហ៍នោះ ដែលបានធ្វើឡើងដោយផ្ទុយពីបញ្ញត្តិនៃ មាត្រា

[39] មាត្រា១៥ នៃច្បាប់ស្តី ពីអាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩

[40] មាត្រា៩៦៣ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ២០០៧

៩៦០ នៃក្រមរដ្ឋប្បវេណីដែលមានចែងអំពី ការលុបចោលអាពាហ៍ពិពាហ៍ ដែលមិនត្រឹមត្រូវតាមច្បាប់កំណត់។ ការដាក់ពាក្យបណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ គឺ គ្រាន់តែទៅកាន់ សាលាដំបូង រាជធានី ខេត្ត របស់ភាគីរស់នៅ។

**៣.២.៣. តំណាងអយ្យការ**

តំណាងអយ្យការ អាចដាក់ពាក្យបណ្តឹង ទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍ សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការ អំពីការបានទទួលពាក្យបណ្តឹងរដ្ឋប្បវេណី[41]។ លើសពីនេះទៅទៀត ប្រសិនបើយល់ឃើញថា ចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ ទោះបីជាគ្មានការជូនដំណឹងពីតុលាការក៏ដោយ ក៏តំណាងអយ្យការអាចចូលរួមក្នុងនីតិវិធី នៃបណ្តឹងរដ្ឋប្បវេណី និង បញ្ចេញយោបល់បានដែរ[42]។ ទោះជាយ៉ាងណាក៏ដោយ ការចូលរួមរបស់តំណាងអយ្យការ ត្រូវបានកម្រិតត្រឹមតែរឿងក្តីណាដែលមានភាពចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈតែបណ្ណោះ។ ក្នុងករណីដែលភាគីជាអនីតិជន អ្នកដែលមានតួនាទីត្រូវការពារភាគីនោះ មិនមែនជាតំណាងអយ្យការទេ តែគឺជាអ្នកតំណាងដែលច្បាប់បានកំណត់ ដូចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលជាអាទិ៍ ដែលត្រូវដើរតួនាទីជាអ្នកការពារសិទ្ធិក្នុងនីតិវិធីរបស់ភាគីតំណាងអយ្យការដែលជាអ្នកតំណាងឲ្យផលប្រយោជន៍សាធារណៈ សិទ្ធិទាមទារឲ្យលុបចោលរបស់តំណាងអយ្យការនោះត្រូវរលត់ ប្រសិនបើសហព័ន្ធម្ខាង ទទួលមរណៈភាព។

[41] មាត្រា៦ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[42] មាត្រា៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

# ជំពូកទី២
# នីតិវិធីមោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

- **បណ្ដឹងទាមទារឲ្យមោឃភាពអាពាហ៍ពិពាហ៍**

ជាទូទៅ កិច្ចសន្យាដែលមានមូលហេតុមោឃភាព កិច្ចសន្យានោះពុំមានអានុភាពតាំងពីដំបូង ពោលគឺ អានុភាពនៃមោឃភាព ត្រូវកើតឡើងដោយស្វ័យប្រវត្តិ ដោយមិនត្រូវការសេចក្ដីសម្រេចរបស់តុលាការនោះទេ។

អានុភាពនៃមោឃភាពអាពាហ៍ពិពាហ៍ ក៏មិនខុសពី អានុភាពនៃមោឃភាពកិច្ចសន្យាធម្មតាដែរ ពោលគឺ មោឃភាពអាពាហ៍ពិពាហ៍កើតឡើងដោយស្វ័យប្រវត្តិនៅពេលដែលមានមូលហេតុមោឃភាព។ ទោះបីជា អាពាហ៍ពិពាហ៍ ត្រូវបានមោឃៈ ប៉ុន្តែអានុភាពនេះ មិនបានធ្វើឲ្យបាត់បង់អានុភាពនៃការចុះបញ្ជីទេ ហេតុនេះ លុះត្រាតែធ្វើបណ្ដឹងបញ្ជាក់អំពីមោឃភាព ទើបអាចលុបចោលនូវការចុះបញ្ជីអាពាហ៍ពិពាហ៍បាន។

ការទាមទារឲ្យបញ្ជាក់អំពីមោឃភាព ត្រូវធ្វើតាមផ្លូវតុលាការ ផ្អែកតាមច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល[43]។ មោឃភាពអាពាហ៍ពិពាហ៍ ទោះបីជា ពុំមានការកើតឡើងនូវអាពាហ៍ពិពាហ៍តាមច្បាប់ក៏ដោយ មានករណីដែលរូបភាពនៃអាពាហ៍ពិពាហ៍ជាក់ស្ដែងបានកើតឡើង ហេតុនេះដើម្បីបញ្ជាក់ច្បាស់ថា គ្មានអាពាហ៍ពិពាហ៍ អាចធ្វើបណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃអាពាហ៍ពិពាហ៍បាន។ បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាព គឺជាបណ្ដឹងទាមទារឲ្យតុលាការចេញនៅសាលក្រម ដើម្បីបញ្ជាក់អំពីការមិនកើតឡើងនៃអាពាហ៍ពិពាហ៍តាមច្បាប់សារធាតុ[44]។

- **បណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍**

ភាគីដែលមានបំណងចង់ទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ ត្រូវដាក់ពាក់បណ្ដឹងទាក់ទងនឹងឋានៈបុគ្គល[45]។ បណ្ដឹងទាក់ទងទៅនឹងឋានៈបុគ្គល មានគោលបំណងបង្កើត ឬ បញ្ជាក់នូវអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងឋានៈបុគ្គល ពោលគឺសំដៅទៅលើបណ្ដឹងដែលបង្កើត អនុភាពនូវការបង្កើត អនុភាពកំណត់ជាស្ថាពរនូវអត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងឋានៈបុគ្គលបច្ចុប្បន្នកាល ឬ អតីតកាល តាមរយៈសាសក្រម ឬ សាសដីកាស្ថាពរដែលទទួលស្គាល់នូវការ ទាមទារក្នុងបណ្ដឹង នោះដូចជាបណ្ដឹងបញ្ជាក់អំពី អត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ឬ នត្ថិភាពនៃទំនាក់ទំនងបិតុភាព ( មាតុភាព )ជាដើម។ បណ្ដឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ គឺជាបណ្ដឹងទាមទារឲ្យតុលាការចេញសាលក្រមប្រការរលត់នូវចំណងអាពាហ៍ពិពាហ៍

[43] មាត្រា៣ ចំណុច ក នៃច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

[44] ច្បាបប់សារធាតុ គឺជាច្បាប់បង្កើតឡើងឲ្យនិយមន័យ កំណត់អំពីសិទ្ធិ និង ករណីកិច្ចរបស់ភាគី

[45] មាត្រា៣ នៃច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

ដោយផ្អែកលើកមូលហេតុនៃការបង្កើតទំនាក់ទំនង គត្តិយុត្ត។ ជាគោលការណ៍សម្មភាពនៃបណ្ដឹងនេះ ត្រូវធ្វើឡើងតាមវិធីដាក់ពាក្យបណ្ដឹង។

## ផ្នែកទី១៖ យុត្តាធិការតុលាការ

សមត្ថកិច្ចសាលាជម្រះក្ដីដែលកំណត់តាមទីកន្លែង ចំពោះបណឹងទាក់ទងឋានៈបុគ្គល គឺជាសម្ថកិច្ចផ្ដាច់មុខ។ ការកំណត់ជាស្ថាពរនូវទំនាក់ទំនងប្ដីប្រពន្ធ តាមបណ្ដឹងទាមទារឲ្យបញ្ជាក់ពីមោឃភាពអាពាហ៍ពិពាហ៍ និងការលុបចោលអាពាហ៍ពិពាហ៍ មានលក្ខណៈជាផលប្រយោជន៍សាធារណៈ ហេតុដូច្នេះហើយ ចាំបាច់សម្របទៅនឹងតម្រូវការរបស់តុលាការ ក្នុងការស្វែងរកការពិតជាក់ស្ដែង ព្រមទាំងតម្រូវការក្នុងការដោះស្រាយវិវាទទាំងស្រុង តាមរយៈការវិនិច្ឆ័យតែមួយលើក។ ហេតុនេះហើយចាំបាច់ត្រូវកំណត់ឲ្យបានច្បាស់លាស់ នូវតុលាការដែលចាត់ការបណ្ដឹងទាមទារឲ្យបញ្ជាក់ពីមោឃភាពអាពាហ៍ពិពាហ៍ និងការលុបចោលអាពាហ៍ពិពាហ៍នោះ ហើយត្រូវប្រមូលផ្ដុំនូវបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលដែលអាចប្ដឹងដោយបុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ច្រើននាក់ ហើយធ្វើការកំណត់នូវ ដែនសមត្ថកិច្ចរបស់តុលាការឲ្យបានច្បាស់លាស់ដោយកំណត់យកទីកន្លែងដែលអាចមានសាមីភាគី ញាតិ ឬ មិត្តភ័ក្តិ ជាអាទិ៍ ដែលជាភស្តុតាងល្អៗ ដើម្បីសម្រួលនូវការធ្វើការអះអាង និង បញ្ជាក់របស់ភាគី និង សម្រួលនូវការស្រាវជ្រាវដោយឆន្ទានុសិទ្ធរបស់តុលាការ គឺជាការសមរម្យ។ បណ្ដឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅសំនៅឋានរបស់ភាគីនៃទំនាក់ទំនងនឹងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្ដឹងនោះ ឬ លំនៅឋាននៅពេលដែលភាគីនោះទទួលមរណភាព[46]។ ប៉ុន្ដែបើលំនៅឋានរបស់ភាគីពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋានរបស់ព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេសមត្ថកិច្ចសាលាជម្រះក្ដីត្រូវកំណត់តាមទីសំណាក់។ បើពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះត្រូវកំណត់តាមលំនៅឋានចុងក្រោយ[47]។ ក្នុងករណីមិនអាចកំណត់តុលាការមានសមត្ថកិច្ចបាន បណ្ដឹងទាក់ទងទៅនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់សាលាដំបូងរាជធានីភ្នំពេញ[48]។ ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ ដើម្បីជៀសវាងពីការយឺតយ៉ាវរបស់នីតិវិធី ឬដើម្បីឲ្យមានសមធម៌រវាងភាគី គឺតុលាការអាចផ្ទេរបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលទាំងមូល ឬផ្នែកណាមួយ ទៅតុលាការផ្សេងទៀតដែលមានសមត្ថកិច្ចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធបានដោយពិចារណាអំពីលំនៅឋានរបស់ភាគី និងសាក្សី និងសាក្សីដែលត្រូវសាកសួរ និងកាលៈទេសៈផ្សេងៗទៀតទោះបីបណ្ដឹងនោះស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ[49]។

---

[46] មាត្រា៥ កថាខណ្ឌទី១ នៃច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

[47] មាត្រា៥ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

[48] មាត្រា៥ កថាខណ្ឌទី៣ នៃច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

[49] មាត្រា៦ នៃច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

## ១.១ ការដាក់ពាក្យបណ្តឹង

### ១.១.១. របៀបដាក់ពាក្យបណ្តឹង

ពេលដែលភាគី ឬ សាច់ញាតិរបស់ភាគី ឬ ជនដែលមានផលប្រយោជន៍ណាមួយ បានដឹងអាពាហ៍ពិពាហ៍បានកើតឡើងដោយ បានបំពានលក្ខខណ្ឌណាមួយ បុគ្គលនោះអាចដាក់ពាក្យបណ្តឹងទៅតុលាការបាន។ នីតិវិធីបណ្តឹងត្រូវបានចាប់ផ្តើមពីពេលដែលមានការការពាក្យបណ្តឹងកើតឡើង។ ការប្តឹង ត្រូវធ្វើដោយដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរ ទៅតុលារការ។ ការទាមទារឲ្យភាគីប្តឹង ដោយដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរ ដោយហេតុថា នីតិវិធីនៃបណ្តឹងទាមទារឲ្យមានភាពច្បាស់លាស់។

### ១.១.២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង

- **ចំណុចចាំបាច់ដែលត្រូវសរសេរបញ្ជាក់**

ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង មានន័យថា ជាចំណុចដែលត្រូវបានសរសេរ ដើម្បីឲ្យពាក្យបណ្តឹងមានសុពលភាព ហើយនៅពេលដែលកង្វះចំណុចនោះ ពាក្យបណ្តឹងគ្មានសុពលភាពឡើយ មានន័យថា ពេលខ្វះចំណុចចាំបាច់ដែលត្រូវសរសេរក្នុងបណ្តឹង តុលាការបង្គាប់ឲ្យកែតម្រូវចំណុចខ្វះខាតនោះ ប៉ុន្តែប្រសិនបើមិនកែតម្រូវទេ តុលាការលើចោលបណ្តឹងនោះ ដោយដីការសម្រេច[50]។

ចំណុចចាំបាច់ដែលត្រូវសរសេរក្នុងពាក្យបណ្តឹងមាន៖

- ពាក្យបណ្តឹងត្រូវធ្វើជាលាយលក្ខណ៍អក្សរ (អាចផ្ទាល់មាត់រឿងក្តីទឹកប្រាក់តិច)[51] ត្រូវធ្វើយ៉ាងតិចចំនួន ០២ច្បាប់
- ឈ្មោះ ឬ នាមករណ៍ និង អាស័យដ្ឋានរបស់ភាគី ព្រមទាំង អ្នកតំណាងច្បាប់បានកំណត់
- ខ្លឹមសារនៃសាលក្រមដែលដើមចោទ ទាមទារឲ្យតុលាការចេញ (ការទាមទារ)
- អង្គហេតុចាំបាច់ដើម្បីបញ្ជាក់ការទាមទារ (កម្មវត្ថុនៃបណ្តឹង)

- ចំណុចផ្សេងៗទៀតក្រៅពីចំណុចចាំបាច់សរសេរក្នុងពាក្យបណ្តឹង

ដើម្បីទទួលស្គាល់នូវសុពលភាពនៃពាក្យបណ្តឹង ត្រូវសរសេរនូវចំណុចដែលចាំបាច់ដូចបានរៀបរាប់ខាងលើ ដូចនេះ ចំណុចផ្សេងទៀត សរសេរ ឬ មិនសរសេរ ពុំមានបញ្ហាកើតឡើងនោះទេ មានថា ចំណុចផ្សេងទៀតក្រៅពីចំណុចដែលដែលចាំបាច់ ទោះបីជាមិនសរសេរក៏ដោយ មិនមែនជាមូលហេតុនៃការលើចោលបណ្តឹងទេ ដូចជា អង្គហេតុដែលជាមូលហេតុនៃការទាមទារ អង្គហេតុសំខាន់ៗ ដែលពាក់ព័ន្ធនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាងដែលត្រូវបញ្ជាក់ពាក្យបណ្តឹង ឲ្យមានសុពលភាព។ ប៉ុន្តែដើម្បីឲ្យមានភាព

[50] មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[51] មាត្រា២២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ច្បាស់លាស់នូវចំណុចវិវាទពេលវេលា នៅក្នុងពាក្យបណ្តឹងគប្បីសរសេរលំអិតនូវចំណុចទាំងនេះ ដើម្បីជាមូលដ្ឋាននៃការឆ្លើយតបរបស់ចុងចម្លើយ និង ជៀសវាងការយឺតយ៉ាវ។

- អង្គហេតុដែលមូលហេតុនៃការទាមទារ និង ត្រូវមានការបញ្ជាក់ភស្តុតាង[52]
- ផ្តិតស្នាមម្រាមដៃ ឬ ចុះហត្ថលេខា និង ឈ្មោះអ្នកប្តឹង
- កាលបរិច្ឆេទ ហត្ថលេខា

## ១.២. ការបង់ពន្ធប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តី គឺជាប្រាក់ពន្ធ ឬសោហ៊ុយដែលភាគីត្រូវបងសម្រាប់ចាត់ការរឿងដីរបស់ខ្លួនទៅតុលាការតាមបញ្ញត្តិច្បាប់។ ប្រាក់ប្រដាប់ក្តីត្រូវធនាគារ ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ដែលបានទាមទារក្នុងបណ្តឹងនេះ។ ការទាមទារច្រើនចំណុចក្នុងបណ្តឹងតែមួយ តម្លៃសរុបនៃការទាមទារទាំងនោះ ត្រូវបានចាត់ទុកជាតម្លៃកម្មវត្ថុនៃបណ្តឹង[53]។ ក្នុងករណីដែលមានការពិបាកក្នុងការគណនាតម្លៃដែលបានកំណត់ខាងលើតុលាការត្រូវកំណត់តម្លៃនោះ ដោយឆន្ទានុសិទ្ធិសមហេតុផល។ បើតម្លៃនោះមិនអាចគណនាបានទេ ខ្ញុំត្រូវចាត់ទុកថា មានចំនួន ៥.៥០០.០០០(ប្រាំលាន់ ប្រាំសែន) រៀល[54]។

### ១.២.១. ប្រភេទប្រាក់ប្រដាប់ក្តី

**ពន្ធពាក្យសុំ៖** គឺជាប្រាក់ពន្ធដែរភាគីត្រូវបងក្នុងការដាក់ពាក្យបណ្តឹង ឬពាក្យសុំសម្រាប់ចាត់ការក្នុងរឿងក្តីរបស់ខ្លួនទៅតុលាការតាមបញ្ញត្តិច្បាប់រួមមាន ពន្ធដាក់ពាក្យបណ្តឹង និងពន្ធដាក់ពាក្យសុំ។ ចំនួនទឹកប្រាក់ដែលត្រូវបង់ពន្ធ ត្រូវគណនាទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹង[55]។ ការបង់ពន្ធត្រូវធ្វើ ដោយការបងជាប្រាក់នៅកន្លែងទទួលពាក្យនៃតុលាការ។ ពាក្យសុំដែរមិនបានបង់ពន្ធនៅពេលដាក់ទេ ត្រូវចាត់ទុកជាពាក្យសុំមិនស្របច្បាប់[56]។

**ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ៖** គឺជាប្រដាប់ក្តីតុលាការដែលភាគី ឬបុគ្គលដែលទាក់ទង និងរឿងក្តីត្រូវបងជាមុនសម្រាប់ការចំណាយរបស់តុលាការ ដែលធ្វើសកម្មភាពតាមនីតិវិធីនៅក្នុងបណ្តឹងរដ្ឋប្បវេណី។ សកម្មភាពនីតិវិធី នៅក្នុងបណ្តឹងរដ្ឋប្បវេណីមានដូចជា ៖ ការពិនិត្យ ភស្តុតាង ការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងៗតាមនិតិវិធីក្នុងបណ្តឹងរដ្ឋប្បវេណី សោហ៊ុយ សម្រាប់ការធ្វើដំណើរ ស្នាក់នៅរបស់ចៅក្រម ក្រឡាបញ្ជី ក្នុងការពិនិត្យភស្តុតាង ស្រាវជ្រាវអង្គហេតុ សាកសួរសាក្សី ដែលប្រព្រឹត្តនៅក្រៅតុលាការ[57]។

---

[52] មាត្រា៧៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[53] មាត្រា៦០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[54] មាត្រា៦០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[55] មាត្រា៦១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[56] មាត្រា៦១ កថាខណ្ឌទី៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[57] មាត្រា៦២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

**ប្រាក់ប្រដាប់ក្ដីភាគី៖** ជាប្រភេទមួយនៃប្រាក់ប្រដាប់ក្ដីដែលកំណត់ដោយតុលាការ ដែលគិតពិចារណានៅលក្ខណៈនៃរឿងក្ដី ឬ លទ្ធផលទ្រព្យធនរបស់ភាគីជាអាទិ៍ សម្រាប់ថ្លៃធ្វើលិខិត បណ្ដឹង លិខិតពាក្យសុំ សោហ៊ុយធ្វើដំណើរ ឬសោហ៊ុយផ្សេងៗ[58]។

**១.២.២. បន្ទុកនៃប្រាក់ប្រដាប់ក្ដី**

បន្ទុកនៃប្រាក់ប្រដាប់ក្ដីត្រូវធ្លាក់ទៅលើ៖

- ភាគីចាញ់ក្ដី ប៉ុន្តែបើចាញ់មួយភាគ តុលាការត្រូវសម្រេចដោយឆន្ទានុសិទ្ធិ
- ភាគីឈ្នះក្ដី បើភាគីនោះប្រព្រឹត្តដោយសកម្មភាពមិនចាំបាច់ ឬធ្វើអោយនីតិវិធីយឺតយ៉ាវ
- សហបណ្ដឹង ត្រូវទទួលបន្ទុកស្មើគ្នា ឬដោយសាមគ្គី ប៉ុន្តែអាចឱ្យភាគីសហបណ្ដឹងទទួលបន្ទុកច្រើនជាងសហបណ្ដឹងផ្សេងទៀតបាន គណនេយ្យដែលភាគីសហបណ្ដឹងនោះប្រព្រឹត្តិសកម្មភាពដែលមិនចាំបាច់
- អ្នកតំណាងដែលច្បាប់កំណត់ អ្នកតំណាងដោយអាណត្តិ ឬក្រឡាបញ្ជីបានធ្វើឱ្យចំនួនទឹកប្រាក់ប្រដាប់ក្ដីដោយគ្មានផលប្រយោជន៍កើតឡើង ដោយចេតនា ឬដោយមានកំហុសធ្ងន់ធ្ងររបស់ខ្លួនត្រូវសងប្រាក់ប្រដាប់ក្ដីនោះវិញដោយដីកាសម្រេចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិ[59]។

ក្នុងនីតិវិធីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានតំណាងអយ្យការជាភាគី ប្រាក់ប្រដាប់ក្ដីក្នុងតំណាងអយ្យការត្រូវទទួលបន្ទុក ជាបន្ទុករបស់រដ្ឋ[60]។ តំណាងអយ្យការក៏ជាអ្នកចូលរួមជាភាគីក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលដែរ ដើម្បីសម្រេចនូវផលប្រយោជន៍សាធារណៈក្នុងការបង្កើត ឬការបញ្ជាក់នូវទំនាក់ទំនងឋានៈបុគ្គលក្នុងករណីដែលគ្មានភាគីនៃទំនាក់ទំនងឋានៈបុគ្គល ដូចនេះទោះជាតំណាងអយ្យការបានចាញ់ក្ដីក៏ដោយ ក៏មិនគួរឲ្យតំណាងអយ្យការទទួលបន្ទុកនូវប្រាក់ប្រដាប់ក្ដីដោយផ្ទាល់ខ្លួនដែរ។

## ១.៣. ការចាត់ចែងពាក្យបណ្ដឹង

ពេលមានវិវាទ ឬហេតុផលដែលឈានដល់ការប្ដឹងលុបចោលអាពាហ៍ពិពាហ៍កើតឡើង ភាគីដើមចោទនឹងធ្វើការដាក់ពាក្យបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ច ក្នុងគោលបំណងទាមទារកម្មវត្ថុពីចុងចម្លើយដែលទាក់ទងនឹងវិវាទនោះ។ ការណ៍នៃការទទួលពាក្យបណ្ដឹង ការពិនិត្យពាក្យបណ្ដឹង ការបញ្ជូនពាក្យបណ្ដឹង និងការកំណត់កាលបរិច្ឆេទត្រៀមសម្រាប់ទាញហេតុផលផ្ទាល់មាត់ មិនមានបញ្ញត្តិពិសេសសម្រាប់អនុវត្តក្នុងនីតិវិធីបណ្ដឹងទាក់ទងឋានៈបុគ្គលទេ ហេតុនេះការអនុវត្ត ត្រូវយកតាមវិធានដែលមានបញ្ញត្តនៅក្នុងនីតិវិធីបណ្ដឹងធម្មតា ពោលគឺក្រមនីតិវិធីរដ្ឋបវេណី។

[58] មាត្រា៦៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[59] មាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[60] មាត្រា១០ នៃច្បាប់ស្ដីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

### ១.៣.១. ការទទួលពាក្យបណ្តឹង

ពាក្យបណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ជាលាយលក្ខណ៍អក្សរ ដែលដាក់ដោយដើមចោទទៅតុលាការ ត្រូវបានក្រឡាបញ្ជីដែលទទួលពាក្យបណ្តឹងនោះបោះត្រា ដែលមានចុះថ្ងៃ ខែ ឆ្នាំទទួលពាក្យបណ្តឹង ដើម្បីបញ្ជាក់ពីពេលវេលានៃការដាក់ពាក្យបណ្តឹងនោះត្រូវធ្វើឲ្យច្បាស់ ហើយធ្វើសំណុំរឿងនៃបណ្តឹងនោះ ដោយបន្ថែមក្រម ព្រមទាំងចុះលេខបណ្តឹង។ បន្ទាប់មកក្រឡាបញ្ជីត្រូវបែងចែកសំណុំរឿងនៅបណ្តឹងនោះ ទៅឲ្យចៅក្រមដែលត្រូវទទួលបន្ទុករឿងក្តីនោះ តាមលំដាប់លំដោយនៃការបែងចែករឿងក្តីដែលកំណត់ប្រចាំឆ្នាំ ដោយប្រធានតុលាការ។ ករណីចៅក្រមទទួលបន្ទុកមានធុរៈ មិនអាចចាប់ការបណ្តឹងនោះបានទេ ត្រូវបែងចែកទៅឱ្យចៅក្រមសេងទៀត ទៅតាមលំដាប់សម្រាប់ជំនួស តែត្រូវបានកំណត់ជាមុន ដោយប្រធានតុលាការ[61]។ ការបែងចែករឿងក្តីនៅតុលាការមួយ និង លំដាប់សម្រាប់ជំនួសមិនឲ្យត្រូវប្តូរនៅក្នុងឆ្នាំនោះបានឡើយ លុះត្រាតែមានមូលហេតុដែលពុំអាចជៀសវាងបាន។ មូលហេតុនោះរួមមាន៖ ចៅក្រមណាម្នាក់មានការងារច្រើនពេក ឬ ករណីចៅក្រមត្រូវឈប់ ឬ ប្តូរទៅតុលាការផ្សេង ករណីដែលចៅក្រមបន្តមានធុរៈ ដោយសារហេតុផលដូចដូចជាត្រូវឈប់សម្រាកក្នុងរយៈពេលវែងជាអាទិ៍។ ការផ្លាស់ប្តូរចំពោះករណីនេះត្រូវកំណត់ដោយដីការ សម្រេចរបស់ប្រធានតុលាការ ។

### ១.៣.២. ការពិនិត្យពាក្យបណ្តឹង

ក្រោយទទួលបានពាក្យបណ្តឹង ចៅក្រមទទួលបន្ទុកដែរបានទទួលការចាត់តាំង ត្រូវធ្វើការពិនិត្យ អំពីភាពសមស្រប ឬ មិនសមស្របនៃពាក្យបណ្តឹង ដោយពិនិត្យលើលក្ខខណ្ឌទម្រង់ ( ចំណុចដែរត្រូវសរសេរក្នុងពាក្យបណ្តឹង ) និងពន្ធដាក់ពាក្យបណ្តឹង។

បើពិនិត្យឃើញថា មានការខ្វះខាតចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្តឹង ឬ មិនបានបងពន្ធពាក្យសុំ ចៅក្រមត្រូវចេញដីកាបង្គាប់ឲ្យកែតម្រូវ ដោយមានកំណត់អំឡុងពេលសមស្របមួយ។ ប្រសិនបើដើមចោទមិនបានធ្វើការកែតម្រូវក្នុងអំឡុងពេលដែលមានកំណត់ទេ តុលាការត្រូវលើកតើពាក្យបណ្តឹងដោយដីកាសម្រេច[62]។ បើមានការមិនពេញចិត្តនឹងដីកាសម្រេចនេះ ដើមចោលអាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍បាន។ តុលាការអាចបង្គាប់ឲ្យបងប្រាក់ប្រដាប់ក្តីក្រៅពីប្រពន្ធ សម្រាប់កោះហៅភាគីដោយកំណត់អំឡុងពេលសមរម្យ។ បើមិនបានបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធទេ តុលាការអាចចេញដីកាសម្រេចលើកបណ្តឹងនោះចោលដោយគ្មានការតវ៉ាពីចុងចម្លើយ តែដីកានេះអាចប្តឹងជំទាស់បាន[63]។

[61] មាត្រា២៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[62] មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[63] មាត្រា៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

### **១.៣.៣. ការបញ្ជូនពាក្យបណ្តឹង**

ក្រោយពីទទួលពាក្យបណ្តឹង បើតុលាការទទួលស្គាល់ថា ពាក្យបណ្តឹងនោះត្រឹមត្រូវតាមទម្រង់ហើយ ក្រឡាបញ្ជីត្រូវទទួលបន្ទុកការបញ្ជូនពាក្យបណ្តឹងនោះ[64] ទៅឱ្យចុងចម្លើយ។

**ការបញ្ជូនមានច្រើនប្រភេទដូចជា៖**

**ការបញ្ជូនដោយប្រគល់** ៖ គឺបញ្ជូនដោយប្រគល់តម្រូវធ្វើឡើងដោយវិធីប្រគល់នូវឯកសារទៅឱ្យជនដែលត្រូវទទួលការបញ្ជូននោះ[65]។ ករណីអ្នកទទួលការបញ្ជូនមិនចេះអក្សរ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនគប្បីពន្យល់នូវខ្លឹមសារនៃឯកសារនៅពេលប្រគល់។

**ការបញ្ជូនដោយការជួបប្រទះ** ៖ បើជនដែលត្រូវទទួលបានការបញ្ជូន ពុំច្បាស់ថាមានលំនៅឋាន ឬទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនឱ្យធ្វើបាននៅទីកន្លែងដែលជួបជននោះ លើកលែងតែក្នុងករណីដែលមានការជូនដំណឹងអំពីទីកន្លែងដែរ ត្រូវធ្វើការបញ្ជូន នោះមន្ត្រីទទួលបន្ទុកការបញ្ជូន ត្រូវបញ្ជូនទៅកាន់ទីកន្លែងដែលបានជូនដំណឹងនោះ[66]។ ម្យ៉ាងទៀតទោះបី មានលំនៅឋានទីសំណាក់ ទីកន្លែងអាជីវកម្ម ឬមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវទទួលការបញ្ជូនក៏ដោយ មន្ត្រីទទួលបន្ទុកការបញ្ជូនក៏អាចបញ្ជូនទៅទីកន្លែងដែលបានជួបប្រទះជននោះបានដែរ បើជននោះមិនប្រកែកចំពោះការទទួលការបញ្ជូននោះ។

**ការបញ្ជូនដោយបង្គ្រប់កិច្ច** ៖ ក្នុងករណីមិនអាចជួយជនដែលត្រូវបានទទួលការបញ្ជូននូវទីកន្លែងដែលត្រូវទទួលការបញ្ជូនទេ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូនអាចប្រគល់ឯកសារនោះទៅអ្នកបម្រើ ឬ បុគ្គលផ្សេងទៀតធ្វើការនៅទីនោះដែលមានការយល់ដឹងសមស្រប ក្នុងការទទួលឯកសារ[67]។ បុគ្គលដែលចាប់ទុកថាមានការយល់ដឹងសមស្រប ត្រង់ចំណុចនេះសំដៅលើអ្នកដែលយល់អំពីអត្ថន័យនៃការបញ្ជូនសារៈសំខាន់នៃការបញ្ជូន និងមានសមត្ថភាពអាចយកឯកសារនោះទៅប្រគល់ឲ្យជនដែលដែលត្រូវទទួលការបញ្ជូន។

**ការបញ្ជូនដោយទុកចោល** ៖ ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន ឬ ជនដែលទទួលការបញ្ជូនដោយបង្គ្រប់កិច្ចតាមមាត្រា ២៥២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវទេ។ មន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន អាចផ្ទុកឯកសារដែលជាកម្មវត្ថុនៃការបញ្ជូននោះចោលនៅទីកន្លែងនោះបាន ដែលការអនុវត្តបែបនេះ មានអនុភាពជាការបញ្ជូននិងត្រូវបានទទួលស្គាល់ដោយច្បាប់ជាធរមាន។

[64] មាត្រា២៤៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[65] មាត្រា២៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[66] មាត្រា២៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[67] មាត្រា២៥២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

**ការបញ្ជូនទៅបរទេស** ៖ បើជនដែលត្រូវទទួលការបញ្ជូនពីទីលំនៅបរទេស ហើយពុំមានទីសំណាក់ កន្លែងជីវកម្ម ឬ ទីស្នាក់ការ ដែលអាចបញ្ជូនបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេការបញ្ជូនប្រភេទនេះ គឺត្រូវបញ្ជូនទៅប្រទេសរបស់ជននោះតាម ២ របៀបគឺ

ករណីជនដែលត្រូវ ទទួលការបញ្ជូនជាជនជាតិបរទេសគប្បីបញ្ជូនដោយប្រគល់ឯកសារឲ្យក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះជាអ្នកអនុវត្តកិច្ចការបញ្ជូន។

ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរតែរស់នៅបរទេស គប្បីបញ្ជូនដោយឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុលរបស់ប្រទេសកម្ពុជា ប្រចាំប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន[68]។ ទោះបីប្រើវិធីណាមួយក្នុងចំណោមវិធីទាំងពីរនោះក៏ដោយ មុននឹងសម្រេចបញ្ជូនឲ្យស្ថាប័នណាជាអ្នកមានតួនាទីក្នុងការបញ្ជូនតុលាការគប្បីពិនិត្យមើល អនុសញ្ញា សន្ធិសញ្ញា ឬ កិច្ចព្រមព្រៀងរវាងប្រទេសកម្ពុជា ជាមួយនឹងប្រទេសនេះ ឬ ការជួយគ្នាទៅវិញទៅមក ក្នុងផ្នែកច្បាប់ ជៀសវាងការអនុវត្តនីតិវិធីនៃការបញ្ជូនខុសពីការកំណត់ ក្នុងសន្ធិសញ្ញា អនុសញ្ញា ឬ កិច្ចព្រមព្រៀងនោះ។ ចំពោះជនបរទេសដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពិធីនៃការបញ្ជូនត្រូវអនុវត្តដូចការបញ្ជូនចំពោះជនជាតិខ្មែរដែរ។

**ការបញ្ជូនតាមការផ្សាយជាសាធារណៈ** ៖ ដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបានគឺ ត្រូវគោរពនូវលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងអស់ ក្រឡាបញ្ជីអាចធ្វើការផ្សាយជាសាធារណៈ និងបន្ទាប់ពីមានការអនុញ្ញាតពីតុលាការ។ ជាគោលការណ៍ដើម្បីអាចធ្វើការបញ្ជូនជាសាធារណៈបាន គឺត្រូវមានការសុំពីភាគី ដែលសុំឲ្យតុលាការធ្វើការបញ្ជូនតាមរយៈ ការផ្សាយជាសាធារណៈ និងបន្ទាប់ពីមានការអនុញ្ញាតពីតុលាការ។ ដើម្បីជៀសវាងការយឺតយ៉ាវតុលាការអាចបង្គាប់ ឲ្យក្រឡាបញ្ជី ធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិបានទោះបីគ្មានឬពាក្យសុំពីភាគីក៏ដោយ[69]។

ដើម្បីធ្វើការបញ្ជូនពាក្យបណ្តឹង ត្រូវទាមទារឲ្យដើមចោទត្រៀមនូវឯកសារចម្លើយ នៃពាក្យបណ្តឹងទៅតាមចំនួន ដែលត្រូវការតាមចំនួននៃចុងចម្លើយ ហើយបញ្ជូនឯកសារសរសេរចម្លើយនៃពាក្យបណ្តឹងនោះ ទៅឲ្យចុងចម្លើយ ចំណែកឯកសារដើម នៅពាក្យបណ្តឹង ត្រូវរក្សាទុកដោយ តុលាការ។

ករណីមិនអាចបញ្ជូនបានដោយហេតុ អស័យដ្ឋានរបស់ចុងចម្លើយ ដែលសរសេរក្នុងពាក្យបណ្តឹងនោះ មិនត្រឹមត្រូវ ឬ មិនបានបងសោហ៊ុយ ចាំបាច់ជាមុន សម្រាប់ធ្វើការបញ្ជូនតុលាការត្រូវបង្គាប់ឲ្យធ្វើការកែតម្រូវដោយកំណត់អំឡុងពេលដើម្បីកែតម្រូវដូចក្នុងករណីដែលមានកង្វះនៅក្នុងការសរសេរក្នុងពាក្យបណ្តឹងដែរ។

[68] មាត្រា២៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[69] មាត្រា២៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ទោះបីជាដើមចោទ បានដាក់ពាក្យបណ្តឹងទៅតុលាការក៏ដោយ ទំនាក់ទំនងគតិយុត្តនឹងកើតមានឡើងរវាងតុលាការ និងដើមចោទប៉ុណ្ណោះ រហូតដល់ពេលដែលពាក្យបណ្តឹងនោះត្រូវបានបញ្ជូនទៅចុងចម្លើយ។ តាមរយៈការបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ នោះចុងចម្លើយនឹងក្លាយជាប្រធាននៃនីតិវិធីនៃបណ្តឹងនោះហើយ ទំនាក់ទំនងគតិយុត្តរវាងភាគីទាំងបី គឺតុលាការដើមចោទនិងចុងចម្លើយ នឹងកើតមានឡើងពីពេលនោះ។ ក្នុងន័យនេះការដាក់ពាក្យបណ្តឹង ត្រូវបានសម្រេចដោយការបញ្ជូនពាក្យបណ្តឹងនោះទៅឱ្យចុងចម្លើយ។

## ផ្នែកទី២៖ ការវិនិច្ឆ័យនៅក្នុងការធ្វើអោយតាពអាពាហ៍ពិពាហ៍ និង ការលុបចោលអាពាហ៍ពិពាហ៍

### ២.១. នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់

ពេលដែលបណ្តឹងបានដាក់តុលាការ ត្រូវធ្វើការកំណត់យ៉ាងឆាប់រហ័សនូវការបរិច្ឆេទ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដែលជាការបរិច្ឆេទលើកដំបូងនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ អំឡុងពេល ៣០ ថ្ងៃ គិតពី ពេលដែលពាក្យបណ្តឹង ត្រូវបានដាក់ នឹងកោះហៅគូភាគីគេចូលសវនាការតាមកាលបរិច្ឆេទនេះ[70]។ ក្នុងទិដ្ឋភាពពិតនៃការអនុវត្តជាក់ស្តែងក្រោយពីបានពិនិត្យហើយទទួលពាក្យបណ្តឹង តុលាការត្រូវកំណត់កាលបរិច្ឆេទ នៃនីតិវិធីនៃការទាញហេតុផលលើកដំបូង ហើយត្រូវធ្វើការបញ្ជូនពាក្យបណ្តឹង ព្រមជាមួយនឹង ដីកាកោះ ហើយចម្លើយឱ្យមកតុលាការ តាមការបរិច្ឆេទកំណត់នេះ។ តុលាការនឹងមិនអាចធ្វើការបញ្ជូនពាក្យបណ្តឹង ព្រមគ្នានឹងដីកាកោះហៅចុងចម្លើយស្តីពីការបរិច្ឆេទលើកដំបូងបានទេ ប្រសិនបើពុំមានការបងសោហ៊ុយជាមុន ហើយពាក្យបណ្តឹងនោះនឹងត្រូវលើកចោលដោយតុលាការ[71]។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ គឺជានីតិវិធីមួយដែលរៀបចំដើម្បីលើកកម្ពស់ និងសម្រួលដល់ការទាញហេតុផលដោយផ្ទាល់មាត់ ក្នុងគោលបំណងធ្វើការបំភ្លឺអំពីចំណុចវិវាទ រវាងភាគីដោយរៀបចំជាមុន នូវសេចក្តីអះអាងរបស់ភាគី និង ធ្វើការរៀបចំនូវភស្តុតាងពាក់ព័ន្ធ នឹងចំណុចវិវាទ ដែលត្រូវធ្វើការពិនិត្យ ។ នៅក្នុងការទាញហេតុផលផ្ទាល់មាត់ ភាគីនីមួយៗតែងតែ លើកឡើងនូវហេតុផលផ្សេងៗដែលខ្លួនយល់ថាមានប្រយោជណ៍សម្រាប់ខ្លួន ដោយមិនបានគិត ដាអង់ហេតុបនេះ មានឬគ្មានសារៈសំខាន់ចំពោះរឿងក្តីនេះ ។ ស្របគ្នាដែរ ភាគីម្ខាងៗតែងតែតវ៉ាចំពោះការលើកឡើងនូវ អង្គហេតុរបស់ភាគីម្ខាងទៀត ហើយតែងតែព្យាយាមដាល់ភស្តុតាងទាំងឡាយដែលខ្លួនគិតថាមានប្រយោជន៍សម្រាប់ខ្លួនឯង ។ ជាលទ្ធផលការធ្វើបែបនេះនាំឲ្យការជម្រះក្តីមានភាពស្មុគស្មាញ ព្រមទាំងអូសបន្លាយដោយឥតប្រយោជន៍ និងធ្វើឲ្យលំបាកក្នុងការស្វែងរកការពិត ។

[70] មាត្រា៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[71] មាត្រា៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ដូច្នេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នៅមុនការជម្រះក្តី ដោយការទាយហេតុផលផ្ទាល់មាត់ ត្រូវរៀបចំនីតិវិធីសម្រាប់ការទាញហេតុផល ដើម្បីទាញការហេតុផលដោយផ្ទាល់មាត់ គ្មានភាំពស្មុគស្មាញ គ្មានអូសបន្លាយពេលដោយឥតប្រយោជន៍ និង ងាយស្រួលក្នុងការស្វែងរកការពិត ដើម្បីឆ្លើយតបនឹងការទទួលខុសត្រូវរបស់តុលាការ ដែលច្បាប់បានបញ្ញាតិដោយតម្រូវឲ្យតុលាការត្រូវប្រឹងប្រែង ដើម្បីតវ៉ាបណ្តឹងរដ្ឋប្បវេណី ឲ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស[72]។

អវត្តមានចុងចម្លើយក្នុងនីតិវិធីតៀមទាញហេតុផលនេះ មិនអាចចាប់ទុកថាជាការសារភាពទេ ពោលគឺតុលាការទុកពេលឲកយចុងចម្លើយក្នុងការចូលរួម ឬមិនចូលរួមក្នុងនីតិវិធីត្រៀមទាញហេតុផលនេះ ហើយគ្រប់ការអះអាងអង្គហេតុរបស់ភាគី ទោះបីជាការសារភាព ឬមិនសារភាព តុលាការអធ្វើការទទួលស្គាល់អង្គហេតុស្របទៅនិងការជាក់ស្តែង ដោយពឹងផ្អែកលើគោលការណ៍ជំនឿទុកចិត្តដោយសេរីភាពខ្លួន ។

## ២.២. ការសម្រេចសេចក្តី(សាលក្រម)

តុលាការចេញសាលក្រមលើបណ្តឹង ដោយសាលក្រមរបស់តុលាការជាន់ទាប ឬសាលដីការបស់តុលាការជាន់ខ្ពស់ ដែលព្រឹត្តការណ៍នេះខុសពីរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ដែលតុលាការចេះសេចក្តីដោយដីកាសម្រេច[73]។

ក្នុងនីតិវិធីបណ្តឹងនេះ តុលាការមិនអនុញ្ញាតឲ្យយកគោលការណ៍នៃការចេញសាលក្រមកំបាំងមុខមកអនុវត្តទេ[74]។ មុនចេញសេចក្តីសម្រេច តុលាការចាំបាច់ត្រូវមានវត្តមានរបស់គូភាគី ក្នុងអង្គសវនាការដើម្បីធានានូវសិទ្ធក្នុងការបញ្ចេញមតិយោបល់ សំណូមពរ ក៏ដូចជាដំណាក់កាល ចុងក្រោយនៃការបញ្ជាកើឲ្យបានច្បាស់លាស់អំពីការទាមទាររបស់ខ្លួន ចំពោះមុខចៅក្រមជំនុំជម្រះ ហើយតុលាការក៏អាចពិចារណាម្តងទៀតទៅលើការអះអាងនេះ ដើម្បីចេញសាលក្រមចុងឲ្យមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ដលើភាគីផ្អែកលើការស្រាវជ្រាវ និងការពិជាក់ស្តែង។

ជាគោលការណ៍ ចំពោះសេចក្តីសម្រេចនៅក្នុងនីតិចិធីបណ្តឹងនីមួយៗ គឺបានកំណត់ពីការផ្ញើ ឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលជាវិធានធានានូវសិទ្ធក្នុងការទទួលបាននូវការជម្រះក្តី ច្រើនថ្នាក់របស់ភាគី ។ តុលាការជាន់ខ្ពស់អាចពិនិត្យមើលនូវសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមបនាតាមពាក្យបណ្តឹងរបស់ភាគីម្ខាង ដែលមិនសុខចិត្តចំពោះសេក្តីសម្រេចនេះ បើសេចក្តីសម្រេចនេះ សម្រេចដោយតុលាការជាន់ទាបមិនត្រឹមត្រូវទេ តុលាការជាន់ខ្ពស់អាចធ្វើការកែប្រែ ឬលុបចោលនូវសេចក្តីសម្រេចនេះ ហើយចេញសេចក្តីសម្រេចថ្មី ។

---

[72] មាត្រា៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[73] មាត្រា៣ នៃច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

[74] មាតា១៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

# ជំពូកទី៣

# អានុភាពនៃមោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍

## ផ្នែកទី១៖ អានុភាពនៃមោឃភាពអាពាហ៍ពិពាហ៍

អានុភាពនៃមោឃភាពអាពាហ៍ពិពាហ៍ នាំឲ្យគ្មានអាពាហ៍ពិពាហ៍ ហេតុនេះ ទំនាក់ទំនងប្តី ប្រពន្ធកូនតាមផ្លូវច្បាប់ មិនយកមកអនុវត្តឡើយចំពោះទំនាក់ទំនងភាគីនៃអាពាហ៍ពិពាហ៍ដែលត្រូវបានមោឃភាព។ តាមក្រមរដ្ឋប្បវេណី ពុំមានបញ្ញត្តិអំពីអានុភាពនៃមោឃភាពចំពោះទំនាក់ទំនងញាតិ ទ្រព្យសម្បត្តិ ឬកូនឡើយ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ អាពាហ៍ពិពាហ៍ដែលមានមូលហេតុមោឃៈ នាំឲ្យភាគីនៃអាពាហ៍ពិពាហ៍ មិនមែនជាប្តីប្រពន្ធនឹងគ្នាទេ ហេតុនេះ បញ្ញត្តិដែលទាក់ទងនឹងករណីកិច្ចរវាងសហព័ទ្ធ កូន សន្តតិកម្ម មិនត្រូវយកមកអនុវត្តឡើយ។ ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ របស់ភាគីនៃអាពាហ៍ពិពាហ៍ដែលត្រូវបានមោឃៈ ការបែងចែក អាចបកស្រាយប្រដូចនឹងករណីលែងលះបាន។

### ១.១. អានុភាពចំពោះទំនាក់ទំនងញាតិ

អានុភាពនៃសាលក្រមបញ្ជាក់ពីមោឃអាពាហ៍ពិពាហ៍ អាចធ្វើឲ្យទំនាក់ទំនងប្តីប្រពន្ធទាំងសងខាងបានបញ្ចប់ ហើយទំនាក់ទំនងផ្សេងៗទៀតៗក៏ត្រូវបានរលាយដូចជា ទំនាក់ទំនងញាតិពន្ធ របស់សហព័ទ្ធរបស់ខ្លួន ឬទំនាក់ទំនងរវាងញាតិលោហិតរបស់ខ្លួនជាមួយនឹងសហព័ទ្ធរបស់ខ្លួន ត្រូវបានរលាយផងដែរ។ ដោយសារតែអាពាហ៍ពិពាហ៍គ្មានអានុភាព នាំឲ្យ ពុំមានទំនាក់ទំនងប្តី និង ប្រពន្ធ (មិនមែនសហព័ទ្ធ) និង ពុំមានទំនាក់ទំនងញាតិពន្ធ[75]។

### ១.២. អានុភាពចំពោះទំនាក់ទំនងបុត្តភាព

#### ១.២.១. ការសន្មតបិតុភាព

នៅពេលដែលចំណងអាពាហ៍ពិពាហ៍ត្រូវបាន រំលាយ ឬ មោឃៈ អានុភាពរបស់អាពាហ៍ពិពាហ៍នោះអាចប៉ះពាល់ទៅដល់កូន ដោយសារតែឪពុកម្តាយត្រូវបានបែកបាក់ ហើយនឹងក្លាយជាអ្នកដទៃ។ ចំពោះទំនាក់ទំនងម្តាយ និង កូន គឺអាចកំណត់បានដោយស្រួល ដោយស្ត្រីដែលបានសម្រាលកូន គឺជាម្តាយរបស់កូន[76]។ ការបង្កើតឲ្យមាននូវមាតុភាពដោយផ្អែកលើអង្គហេតុស្តីពីការសម្រាលកូនដែលជាអង្គហេតុច្បាស់លាស់យ៉ាងជាក់ស្តែង នាំឲ្យកំណត់ម្តាយព្រមពេលជាមួយគ្នានឹងកំណើតរបស់កូន។ ប៉ុន្តែការកំណត់ពីការសន្មតបិតុភាពតាមច្បាប់មិនអាចធ្វើបានទេ ចំពោះទំនាក់ទំនងឪពុក និង កូន ដោយសារតែ អាពាហ៍ពិពាហ៍ គ្មានអានុភាព។ ក្នុងករណីដែលកូនបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែល

[75] មាត្រា៩៣៨ ចំណុច ក និង ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[76] មាត្រា៩៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

អាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីពេលមានចំណងអាពាហ៍ពិពាហ៍ត្រូចសន្មតថា មានគត៌ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍នោះ[77]។

**១.២.២. អំណាចមេបា**

ដោយផ្អែកទៅតាមមាត្រា ៨៨៧ នៃក្រមរដ្ឋប្បវេណី ស្ត្រីដែលសម្រាលកូន គឺជាម្តាយរបស់កូន ហេតុដូច្នេះហើយ វត្តមានរបស់ម្តាយមានភាពច្បាស់លាស់។ ដូច្នេះ ប្រសិនបើស្ត្រីមិនទាន់បានរៀបអាពាហ៍ពិពាហ៍ផ្តល់កំណើតដល់កូន ស្ត្រីនោះក្លាយជាអ្នកដែលមានអំណាចមេបាលើកូននោះ[78]។ ចំពោះកូនដែលត្រូវបានទទួលស្គាល់ ឪពុកអាចក្លាយជាអ្នកដែលមានអំណាចមេបាបាន ក្រោយពេលមានការពិភាក្សារវាងឪពុក និង ម្តាយ[79]។ ដោយសារតែឪពុក និង ម្តាយ មិនបានរៀបអាពាហ៍ពិពាហ៍ទេ ដូច្នេះ ទោះបីជាឪពុកក្លាយជាអ្នកដែលអំណាចមេបាក៏ដោយ ឬ ម្តាយក្លាយជាអ្នកដែលមានអំណាចមេបាក៏ដោយក៏វាមិនមែនជាអំណាចមេបាសហការគ្នាដែរ តែវានៅតែជាអំណាចមេបាទោលដដែល។ ក្នុងករណីឪពុក បានទទួលស្គាល់កូន ឪពុកអាចពិភាក្សាជាមួយម្តាយ ដើម្បីខ្លួនក្លាយជាអ្នកមានអំណាចមេបា ប៉ុន្តែប្រសិនបើ ម្តាយមិនយល់ព្រមទេ ឬ មិនអាចពិភាក្សាគ្នាបានទេ ឪពុកអាចទាមទារទៅតុលាការ ឲ្យកំណត់ថា ខ្លួនជាអ្នកមានអំណាចមេបាចំពោះកូន[80]។

**១.២.៣. សោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូន**

ប្រសិនបើ គ្មានការទទួលស្គាល់កូនទេ ឪពុកពុំមានករណីកិច្ចទទួលបន្ទុកនូវសោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមកូនទេ។ ប៉ុន្តែឪពុកដែលបានទទួលស្គាល់កូន គឺអាចមានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូនបាន។ ម្យ៉ាងវិញទៀត កូនក៏មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយឪពុកដែលមិនបានរស់នៅជាមួយកូនដែរ។ ក្រៅពីការចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន ឪពុកដែលបានទទួលស្គាល់កូននោះ មានករណីកិច្ចទទួលបន្ទុកសោហ៊ុយចាំបាច់ដើម្បីចិញ្ចឹមថែរក្សាកូន[81]។

**១.៣. អានុភាពចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ**

ក្រមរដ្ឋប្បវេណី ពុំមានបញ្ញត្តិអំពីអានុភាពចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ ដែលអាពាហ៍ពិពាហ៍ត្រូវបានមោឃភាពនោះទេ ប៉ុន្តែបញ្ហានេះអាចកើតឡើង ប្រសិនបើ ភាគីនៃអាពាហ៍ពិពាហ៍ដែលត្រូវបានមោឃៈ មានទ្រព្យសម្បត្តិក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ជាមួយគ្នា។

[77] មាត្រា៩៨៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[78] មាត្រា១០៣៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[79] មាត្រា១០៣៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[80] មាត្រា១០៣៨ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[81] មាត្រា១០៤០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ករណីនេះ នៅប្រទេសជប៉ុន ចំពោះបញ្ហាទ្រព្យសម្បត្តិ គេបកស្រាយប្រដូចនឹងករណីលែងលះ ហេតុនេះ ប្រពន្ធទ្រព្យសម្បត្តិប្ដីប្រពន្ធតាមច្បាប់ និង ទំនាក់ទំនងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធជាមួយនឹងតតិយជន ត្រូវបាន យកមកអនុវត្តផងដែរ ចំពោះមោឃភាពអាពាហ៍ពិពាហ៍។

**១.៣.១. ការបែងចែកទ្រព្យសម្បត្តិរួម**

ទ្រព្យរួម គឺសំដៅទៅលើទ្រព្យធនកើតមាននាពេលបច្ចុប្បន្ន នឹង ទ្រព្យកើតមាននាពេលអនាគត់ របស់ សហព័ទ្ធម្នាក់ៗ ផលកម្រៃ នឹងផលទុនរបស់សហព័ទ្ធ ក្នុងលក្ខណៈជាប្រាក់បៀវត្សរ៍ ឬ ប្រាក់ឈ្នួល ឬ ប្រាក់កម្រៃ ឬ ផលប្រយោជន៍នានា ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍[82]។ លើកលែងតែទ្រព្យសម្បត្តិដែលមានមុន ពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យដែលសហព័ទ្ធទទួលបាន ដោយប្រទាកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុង ពេលអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យដោយឡែកផ្សេង ទៀត នឹងត្រូវរាប់ជាទ្រព្យដោយឡែក[83]។ ក្នុងករណីដែលប្ដី មានការងារនៅខាងក្រៅផ្ទះ ហើយប្រពន្ធធ្វើការងារនៅ ក្នុងផ្ទះ ប្ដីមិនអាចបដិសេធចំពោះចំណូលដែលខ្លួនរកបានពីក្រៅផ្ទះ ថាមិនមែនជាទ្រព្យរួម ឬ បន្ថយសិទ្ធិរបស់ ប្រពន្ធលើចំណូលរបស់ខ្លួនឡើយ ដោយជាគោលការច្បាប់ការងារគេហកិច្ចត្រូវចាត់ទុកថា ការងារខាងក្នុងផ្ទះ និង ការងារខាងក្រៅផ្ទះមានតម្លៃស្មើគ្នា។

ចំពោះករណីក្នុងការបែងចែកទ្រព្យសម្បត្តិរួម អាចធ្វើឡើងតាមការព្រមព្រៀងរបស់ភាគី ប៉ុន្តែក្នុងករណី ដែលគ្មានការព្រមព្រៀង ជាគោលការណ៍ គឺតុលាការសម្រេចឲ្យម្នាក់ ១/២ (មួយភាគពីរ) នៃទ្រព្យរួម។ ប៉ុន្តែបើ មានករណីពិសេស និង មានការទាមរបស់ប្ដីប្រពន្ធណាងម្ខាង តុលាក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយ ពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគី នីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើតទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍[84]។

**១.៣.២. ការទទួលខុសត្រូវលើបំណុល**

កាតព្វកិច្ច និង ករណីដែលប្ដី ឬ ប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ជាមួយម្ចាស់បំណុល នៅក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ ប្ដី និង ប្រពន្ធត្រូវទទួលខុសត្រូវរួមគ្នាទៅលើ បំណុលរបស់ខ្លួន[85]។ ក្នុងករណីបំណុលរួមប្ដីប្រពន្ធត្រូវតែទទួលខុសត្រូវរួមគ្នា ទោះបីជាបំណុលនោះប្ដីប្រពន្ធ ទាំងពីរជាអ្នកខ្ចីរួមគ្នា ឬក៏សហព័ទ្ធណាម្នាក់ជាអ្នកខ្ចីតែមានការ ព្រមព្រៀងជាលាយល័ក្ខអក្សរពីសហព័ទ្ធម្នាក់ទៀ ត។ ប៉ុន្តែបើទោះបីជាគ្មានការព្រមព្រៀងជាលាយល័ក្ខណ៍អក្សរពីសហព័ទ្ធម្ខាងទៀតក៏ដោយ ក៏អាចចាត់ទុកថាជា

[82] មាត្រា៩៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[83] មាត្រា៩៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[84] មាត្រា៩៨០ កថាខណ្ឌ ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

[85] មាត្រា៩៧៥ កថាខណ្ឌ ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

បំណុលរួមបានផងដែរ ប្រសិនបើបំណុលនោះស្ថិតក្រោមរូបភាពជាបំណុលដែលជាប់ពាក់ព័ន្ធ នឹងការក្សាជីវភាពរួមរបស់ប្តីប្រពន្ធ ការអប់រំ ការថែទាំ និង ព្យាបាលកូន បំណុលដែលជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រង និង រក្សាទ្រព្យសម្បត្តិរួម។ មិនត្រូវប៉ះពាល់ដល់តតិយជននៅពេលជម្រះទ្រព្យដែលជាអានុភាពនៃមោឃភាពអាពាហ៍ពិពាហ៍។

**ផ្នែកទី២៖ អានុភាពនៃការលុបចោលអាពាហ៍ពិពាហ៍**

អានុភាបប្រតិសកម្មត្រូវបានទទួលស្គាល់ចំពោះ ការលុបចោលនូវសកម្មភាពគតិយុត្តជាទូទៅ ប៉ុន្តែការលុបចោលអាពាហ៍ពិពាហ៍មិនមានអានុភាពប្រតិសកម្មទេ ដោយពិចារណាដល់គុណវិបត្តិដែលត្រូវកើតឡើងចំពោះ ភាគី កូន និង តតិយជន។ ការលុបចោលអាពាហ៍ពិពាហ៍ ពុំមានអានុភាពទៅលើអតីតកាលឡើយ[86] មានន័យថា អាពាហ៍ពិពាហ៍ត្រូវមានសុពលភាព រហូតដល់សេចក្តីសម្រេចរបស់តុលាការដេលសម្រេចលុបចោលចូលជាស្ថាពរហើយទោះបីជាសេចក្តីសម្រេចរបស់តុលាការបានចូលជាស្ថាពរក៏ដោយ ក៏ការលុបចោលនឹងគ្មានអានុភាពទៅលើអតីតកាលទេ ពោលគឺគ្រាន់តែមានអានុភាពរំលាយអាពាហ៍ពិពាហ៍ឆ្ពោះទៅអនាគតប៉ុណ្ណោះ។

**២.១. សំណងនៃការខូចខាត**

នៅពេលដែលបណ្តឹងបានកើតឡើង គឺតែងតែមានផលប៉ះពាល់ណាមួយ ឬ រងនៅការខូចខាច ចំពោះបណ្តឹងដែលទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍វិញក៏មិនខុសគ្នាដែរ។ ចំពោះផលប្រយោជន៍លើទ្រព្យសម្បត្តិដែលភាគីមិនបានដឹងអំពីមូលហេតុនៃការលុបចោល នៅពេលរៀបអាពាហ៍ពិពាហ៍ថ ប្រសិនបើបាបទទួលទ្រព្យសម្បត្តិ ដោយការរៀបអាពាហ៍ ត្រូវសងទ្រព្យសម្បត្តិនោះ ត្រឹមកម្រិតនៃផលប្រយោជន៍ដែលបានទទួល[87]។

ទ្រព្យសម្បត្តិដែលទទួលពីការរៀបអាពាហ៍ពិពាហ៍រួមមាន៖

- ទ្រព្យសម្បត្តិដែលត្រូវបានធ្វើប្រទានកម្មនៅពេលរៀបអាពាហ៍ពិពាហ៍ និង ក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍
- ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈសន្តតិកម្ម និង អច្ច័ទាន
- ព្រមទាំងផលប្រយោជន៍ពីការធានារ៉ាប់រងជីវិត ជាអាទិ៍។

សម្រាប់ផលប្រយោជន៍ទាំងអស់ដែលទទួលដោយការរៀបអាពាហ៍ពិពាហ៍ រួមមានទាំង ផលប្រយោជន៍លើទ្រព្យសម្បត្តិទាំងអស់ ដូចជាថ្លៃចំណាយលើម្ហូបអាហារ និង ការកម្សាន្ត ជាដើម។ ចំពោះភាគីដែលមាននឹងអំពីមូលហេតុនៃការលុបចោលអាពាហ៍ពិពាហ៍ នៅពេលរៀបអាពាហ៍ពិពាហ៍ត្រូវសងផលប្រយោជន៍ទាំងអស់

[86] មាត្រា៩៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[87] មាត្រា៩៦៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ដែលបានទទួលដោយការរៀបអាពាហ៍ពិពាហ៍នោះ ប្រសិនបើភាគីម្ខាងទៀតសុចរិតវិញ ត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតនោះ[88]។

## ២.២. អានុភាពចំពោះបុគ្គល

### ២.២.១. អានុភាពចំពោះសាមីជន

អានុភាពនៃសាលក្រមលុបចោលអាពាហ៍ពិពាហ៍ បានធ្វើឲ្យចំណងអាពាហ៍ពិពាហ៍មានការផ្លាស់ប្តូរ ដែលធ្វើឲ្យជីវិតគូភាគី ទៅជាជីវិតនៅលីវម្តងទៀត គឺដោយសារតែអាពាហ៍ពិពាហ៍ដែលមានអានុភាព ដែលអ្នកទាំងពីរបានបង្កើតមកត្រូវក្លាយជាឥតបានការ។ ហើយចំណងគតិតយុត្តិមួយចំនួនក៏ត្រូវបានរលាយផងដែល ដូចជា ករណីកិច្ចប្តីប្រពន្ធត្រូវរស់នៅជាមួយគ្នា ហើយសហការ និង សង្គ្រោះគ្នាទៅវិញទៅមក[89] និង ការកំណត់នៅពេលរៀបអាពាហ៍ពិពាហ៍ ប្តី ប្រពន្ធ អាចប្រើនាមត្រកូលរបស់ប្តី ឬ ប្រពន្ធ ឬ អាចប្រើនាមត្រកូលដើមរៀងៗខ្លួន[90] ក៏ត្រូវរលាយផងដែរ។ នៅមានបញ្ហាមួយចំនួនទៀតដែលបានកើតឡើង នៃការរំលាយអាពាហ៍ពិពាហ៍របស់ភាគីទាំងពីរផងដែរ នោះគឺជាបញ្ហាបុត្តភាព និង ការបែងចែកទ្រព្យសម្បត្តិ។

### ២.២.២. អានុភាពចំពោះបុត្តភាព

នៅពេលដែលអាពាហ៍ពិពាហ៍ត្រូវបានលុបចោល ឬ ត្រូវបានរំលាយ ដោយហេតុឪពុកម្តាយបានបែកបាក់ ក្លាយទៅជាអ្នកដទៃនឹងគ្នា វានឹងធ្វើឲ្យមានការជះឥទ្ធិពលទៅដល់កូន។ នៅពេលឪពុកម្តាយរស់នៅបែកគ្នា កូនត្រូវនៅជាមួយឪពុកម្តាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ[91]។ ប៉ុន្តែក្នុងករណីដែលការពិភាក្សាមិនបានសម្រេច ឬ ពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាលើផលប្រយោជន៍របស់កូន[92]។

ប្រសិនបើអាពាហ៍ត្រូវបានលុបចោលមុនពេលកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមក។ ក្រោយពេលកំណើតកូន គេអាចកំណត់យកឪពុកមានអំណាចមេបាបាន តាមការពិភាក្សាជាមួយម្តាយរបស់កូន។

ដោយយោងទៅតាមមាត្រា៩៨៨ នៃក្រមរដ្ឋប្បវេណី ចំពោះការសន្មតបិតុភាពដែលទារកទើបនឹងកើតត្រូវធ្វើឡើងដោយៈ

[88] មាត្រា៩៦៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[89] មាត្រា៩៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[90] មាត្រា៩៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[91] មាត្រា១០៣៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[92] មាត្រា១០៣៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

- ទារកនៅក្នុងគភ៌ប្រពន្ធដែលមានកនៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ត្រូចសន្មតថាជាកូនរបស់ប្តី
- កូនដែលបានកើតនៅក្រោយអំឡុងពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ ត្រូវបានបង្កើត ឬ ក្នុងអំឡុងពេល ៣០០ (បីរយ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានរំលាយ ឬ ការលុបចោលអាពាហ៍ពិពាហ៍ ត្រូវសន្មតថា មានគភ៌ នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍
- ក្នុងករណីដែលស្ត្រីបានរៀបអាពាហ៍ពិពាហ៍ថ្មីម្តងទៀតដោយមិនរង់ចាំផុតអំឡុងពេល ១២០ ថ្ងៃ ហើយបានបង្កើតកូនក្នុងអំឡុងពេល ៣០០ ថ្ងៃ ក្រោយពេលដែលអាពាហ៍ពិពាហ៍មុនរលាយ កូនដែលបានកើតមកត្រូវសន្មតថា កូននោះជាកូនរបស់ប្តីដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយ។

ការកំណត់អ្នកមានអំណាចមេបា ឬ ការចាត់ចែងពាក់ព័ន្ធនឹងការបីបាច់រក្សាកូន ត្រូវធ្វើឡើងដោយគិតពិចារណាយ៉ាងសំខាន់ទៅលើសុខុមាសរបស់កូន។ ដូច្នេះ តុលាការត្រូវសួរ និង គិតពិចារណានូវយោបល់ក្នុងការសម្រេចសេចក្តី ដោយមើលទៅតាមអាយុ ឬ ទៅតាមយល់ដឹងរបស់កូននោះ[93]។ ក្នុងករណីដែលអាពាហ៍ត្រូវបានលុបចោល ឪពុករបស់កូន អាទទួលស្គាល់កូនបាន ដោយការទទួលស្គាល់ដោយស្ម័គ្រចិត្ត ប្រសិនបើកូននោះមានឪពុកតាមផ្លូវច្បាប់រួចហើយ ពុំអាចទទួលស្គាល់បានឡើយ[94]។

## ២.៣. អានុភាពទៅលើទ្រព្យសម្បត្តិ

ក្រោយអាពាហ៍ពិពាហ៍ត្រូវបានលុបចោល សហព័ទ្ធទាំងសងខាងតែងតែទាមទារនូវចំណែកទ្រព្យសម្បត្តិរៀងៗខ្លួន ហើយបញ្ហាដែលត្រូវប្រឈមគឺ ការបែងចែកទ្រព្យសម្បត្តិដែលសហព័ទ្ធទាំងសងខាងមាន និងការទទួលខុសត្រូវទៅលើបំណុលដែលសហព័ទ្ធទាំងពីរ។

### ២.៣.១. ការបែងចែកទ្រព្យសម្បត្តិរួម

នៅពេលដែលសហព័ទ្ធជាប្តីប្រពន្ធបានលុបចោលអាពាហ៍ពិពាហ៍របស់ខ្លួន វានិងធ្វើអោយមានការពិបាកក្នុងការបែងចែកទ្រព្យ។ សហព័ទ្ធតែងតែទាមទារចង់បានចំណែកច្រើនរៀងៗខ្លួន ដែលវាជាផលវិបាកក្នុងការដោះស្រាយ។ ដោយផ្អែកលើគំនិត និង ទំនៀមទម្លាប់ប្រពៃណីខ្មែរ ស្ត្រីដែលជាភរិយាលក្រោយពេលរៀបអាពាហ៍ពិពាហ៍ប្រកាន់យកតួនាទីតែមួយគត់ នោះគឺការងារផ្ទះ។ ដោយសារកត្តានេះហើយដែលស្ត្រីមួយចំនួនរងនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរក្រោយពេលអាពាហ៍ពិពាហ៍ត្រូវបានរំសាយ ដោយខ្លួនពុំបានទទួលនូវទ្រព្យសម្បត្តិអ្វីឡើយ ព្រោះខ្លួនពុំបានប្រកបមុខរបរ ឬ រកស៊ីអ្វីទាំងអស់។ ប៉ុន្តែនៅក្នុងពេលបច្ចុប្បន្ន ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[93] មាត្រា២២ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ២០១០

[94] មាត្រា៩៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

បានចែងយ៉ាច្បាស់លាស់អំពីការបែងចែកទ្រព្យសម្បត្តិតាមកិច្ចសន្យា និង ការប្រកាន់យកប្រព័ន្ធទ្រព្យសម្បត្តិដែច្បាប់បានកំណត់។

- **ប្រព័ន្ធសម្បត្តិតាមកិច្ចសន្យា**

ប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យា គឺសំដៅដល់ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅមុន ឬ ក្រោយអាពាហ៍ពិពាហ៍បាន ប៉ុន្តែកិច្ចសន្យានេះ មិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកិច្ច និង ភាគបម្រុងឡើយ[95]។ កិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវបានធ្វើឡើង ដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និង ដើម្បីបញ្ជាក់ឲ្យច្បាស់លាស់អំពីទំនាក់ទំនងសិទ្ធិ និង ករណីកិច្ចរបស់ប្តីប្រពន្ធ គឺសហព័ទ្ធទាំងសងខាងត្រូវបានផ្តល់លទ្ធភាព ដែលអាច កំណត់ដោយខ្លួនឯងនូវ សមាសភាពនសទ្រព្យសម្បត្តិរួម វិធាននៃការគ្រប់គ្រង ព្រមទាំងការជម្រះបញ្ជី និង ការបែងចែករបបបេតិភ័ណ្ឌគ្រួសារ។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធត្រូវធ្វើជាលាយ លក្ខណ៍អក្សរ និង ត្រូវការចុះបញ្ជីឲ្យបានត្រឹមត្រូវ នៅក្រសួងយុត្តិធម៌ ដើម្បីអាចយកទៅតតាំងជាមួយនឹងតតិយជន[96]។ ការធ្វើបែបនេះជាហាក់ដូចជា ពួកគេទាំងពីរបានព្រមព្រៀងគ្នាក្នុងការបែងចែកទ្រព្យសម្បត្តិ តែការជ្រើសរើសយកប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យានេះ អាចផ្តល់ភាពងាយស្រួលដល់ស្ថានប័នតុលាការ ព្រមទាំងជៀសវាងនូវវិវាទវែងឆ្ងាយរវាគូភាគី ពេលបែងចែកទ្រព្យសម្បត្តិក្រោយ ពេលអាពាហ៍ពិពាហ៍ត្រូវបានរំលាយដោយភាគីគ្រាន់តែអនុវត្តតាមបញ្ញាត្តិដែលបានកំណត់ក្នុងកិច្ចសន្យានោះជាការស្រេច។

- **ប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់កំណត់**

ក្នុងករណីដែលសហព័ទ្ធទាំងពីរមិនបានធ្វើកិច្ចសន្យាពិសេសចំពោះទ្រព្យសម្បត្តិនោះទេ ទំនាក់ទំនងទ្រព្យរបស់ភាគីទាំងសងខាង ត្រូវយកតាមប្រព័ន្ធទ្រព្យសម្បត្តិដែលច្បាប់បានកំណត់។ ក្នុងប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធជាពីរប្រភេទគឺ ទ្រព្យសម្បត្តិរួម និង ទ្រព្យសម្បត្តិដោយឡែក។

**ទ្រព្យសម្បត្តិដោយឡែក** គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ ឬ ទ្រព្យដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តិតកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ ទ្រព្យដែលជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែកផ្សេងទៀត[97]។ នៅពេលដែលជីវភាពអាពាហ៍ពិពាហ៍បន្តកាន់តែយូរទៅ មានករណីជាច្រើនដែលទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ និង ទ្រព្យសម្បត្តិដែលទទួលបានអំឡុងពេលរៀបអាពាហ៍ពិពាហ៍ ក្លាយទៅជាមិនអាចបែងចែកច្បាស់លាស់ថាជាទ្រព្យរបស់ខ្លួនផ្ទាល់ ឬ ជាទ្រព្យរួមដែលជាហេតុនាំអោយមានវិវាទក្នុងការបែងចែកទ្រព្យសម្បត្តិ។ ដើម្បីឲ្យ

[95] មាត្រា៩៦៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[96] មាត្រា៩៧០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[97] មាត្រា៩៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

ងាយស្រួលក្នុងការបែងចែកភាគី គប្បីធ្វើជាបញ្ជីទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ដើម្បីបញ្ជាក់ឲ្យបានច្បាស់រវាងទ្រព្យដោយឡែក និង ទ្រព្យរួម។ ទ្រព្យដោយឡែក មិនមែនជាកម្មវត្ថុនៃការបែងចែកនៅពេលដែលអាពាហ៍ពិពាហ៍ត្រូវបានរំលាយនោះទេ ព្រោះទ្រព្យដោយឡែកត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់សហព័ទ្ធតែម្ខាងដែលជាម្ចាស់កម្មសិទ្ធិ។ ក្រោយពេលលុបចោលអាពាហ៍ពិបាហ៍ ភាគីមិនអាចប្តឹងទាមទារឲ្យបែងចែកទ្រព្យសម្បត្តិដោយឡែករបស់ភាគីម្ខាងទៀតបានទេ។

**រីឯទ្រព្យរួម** គឺជាទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើលែងតែទ្រព្យសម្បត្តិដែលកំណត់ថាជាទ្រព្យសម្បត្តិដោយឡែក[98]។ ប្តីប្រពន្ធ មនាសិទ្ធិស្មើរគ្នាក្នុងការប្រើប្រាស់ ទទួលផលប្រយោជន៍ និង គ្របគ្រងទ្រព្យរួម[99] តែការប្រើប្រាស់នោះ ត្រូវស្ថិតក្នុងទំហំដែលចាំបាច់ ដោយផ្អែកលើការចាំបាច់នៅក្នុងជីវិភាព[100]។ ក្នុងករណីអាពាហ៍ពិពាហ៍តត្រូវលុបចោល ហើយគ្មានការព្រមព្រៀងលើការបែងចែកទ្រព្យសម្បត្តិដោយសហព័ទ្ធទាំងសងខាង សហព័ទ្ធនីមួយមានសិទ្ធទទួលយក ១/២ (មួយភាគពីរ) នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែបើមានករណីពិសេស និងការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើតទ្រព្យក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមាន ចំណងអាពាហ៍ពិបាហ៍ អាយុស្ថានភាពផ្លូវចិត្ត និង ផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូលលទ្ធភាពធ្វើការងារ របស់ភាគីនីមួយៗ និង ផលប្រយោជន៍របស់កូនជាអាទិ៍[101]។

### ២.៣.២. ការទទួលខុសត្រូវលើបំណុល

ក្រៅពីការបែងចែកផលប្រយោជន៍លើទ្រព្យសម្បត្តិរួមរបស់សហព័ទ្ធ ក៏មានបញ្ហាផ្សេងទៀតដែលទាក់ទងទៅលើបំណុលដែលសហព័ទ្ធបានជំពាក់គេពីមុនពេលរៀបអាពាហ៍ពិពាហ៍ ឬ បំណុលដែលមានក្នុងអំឡុងពេលមានចំនងអាពាហ៍ពិពាហ៍។ ការបែងចែកទៅចំពោះបំណុលរបស់សហព័ទ្ធ ក៏មានការចែកជាពីផងដែរ គឺបំណុលដោយឡែក និង បំណុលរួម។

**បំណុលដោយឡែក ឬ បំណុលផ្ទាល់ខ្លួន** គឺសំដៅទៅលើបំណុលដែលហព័ទ្ធម្ខាងបានជាប់ជំពាក់នាមុនពេលរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែបើក្នុងករណីដែលសហព័ទ្ធម្ខាងជំពាក់ប្រាក់បំណុលគេ ក្នុងអំឡុងពេលមានអាពាហ៍ពិពាហ៍ ដែលបានឲ្យសហព័ទ្ធម្ខាងទៀតដឹងពីការជំពាក់នោះ តែការខ្ចីប្រាក់នោះ គឺដើម្បីយកទៅប្រើប្រាស់លើផលប្រយោជន៍ផ្ទាល់ខ្លួន ឬ ខ្ចីយកទៅប្រើប្រាស់ដោយអត់ប្រយោជន៍ ដូចនេះបំណុលនោះក៏មិនមាន

[98] មាត្រា៩៧៣ នៃក្រមនីតិរដ្ឋប្បវេណី ២០០៦
[99] មាត្រា៩៧៤កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[100] មាត្រា៩៧៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦
[101] មាត្រា៩៨០ នៃក្រមនីតិរដ្ឋប្បវេណី ២០០៦

ការពាក់ព័ន្ធជាមួយសហព័ទ្ធម្ខាងទៀតឲ្យទទួលខុសត្រូវចំពោះបំណុលនោះឡើយ ជាមួយគ្នានេះដែរ បំណុលដែលអាចចាត់ទុកជាបំណុលផ្ទាល់ លុះត្រាតែសហព័ទ្ធម្ខាងទៀតមានភស្តុតាងផ្ទុយ បើគ្មានការបង្ហាញពីភស្តុតាងផ្ទុយទេ ទោះជាខ្ចីយកទៅធ្វើអ្វីក៏ដោយ ក៏ត្រូវចាត់ទុកថាជាបំណុលរួមដែរ។

**បំណុលរួម** គឺជាបំណុលដែលកើតនៅអំឡុងពេលអាពាហ៍ពិពាហ៍ វាជាកាតព្វកិច្ចរួម របស់សហព័ទ្ធទាំងសងខាង ដោយសារតែបំណុលនោះកើតពីការចំណាយទៅលើការរក្សាជីវភាពរួមរបស់ប្តី ប្រពន្ធ ឬ ចំណាយលើការអប់រំ ឬ ការព្យាបាល ថែទាំកូន ព្រមទាំងកាតព្វកិច្ច និង ករណីកិច្ចផ្សេងៗទៀត ដែលសហព័ទ្ធទាំងសងខាងបានព្រមព្រៀងជាមួយម្ចាស់បំណុល ឬ កាតព្វកិច្ច និង ករណីកិច្ចផ្សេងៗទៀត ដែលមានសហព័ទ្ធណាម្ខាង បានទទួលបន្ទុក ដោយមានការយល់ព្រមពីសហព័ទ្ធ ម្ខាងទៀត។ ការព្រមព្រៀងរបស់ប្តីប្រពន្ធជាមួយម្ចាស់បំណុលត្រូវធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ[102]។

[102] មាត្រា៩៧៥ កថាខណ្ឌ នៃក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦

# សេចក្តីសន្និដ្ឋាន

ឆ្លងការតាមការសិក្សាស្រាវជ្រាវ និង បកស្រាយខ្លឹមសារដែលទាក់ទង នឹងប្រធានបទ "**មោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍**" រួចមកយើងអាចសន្និដ្ឋានបានថា ចំណងអាពាហ៍ពិពាហ៍មួយអាចកើតឡើងបាន លុះត្រាតែភាគីទាំងសងខាងគោរពទៅតាមនីតិវិធីដែលច្បាប់បានចែង ប៉ុន្តែចំណងអាពាហ៍ពិពហ៍ទាំងនោះ នឹងមិនមានអានុភាពទេ នៅពេលដែលមានបណ្តឹងទាមទារឲ្យមោឃភាព បណ្តឹងទាមទារឲ្យលុបចោលអាពាហ៍ពិពាហ៍ និង បណ្តឹងលែងលះ ទោះបីជាមូលហេតុនៃបណ្តឹងទាំងនោះ មានភាពខុសគ្នាក៏ពិតមែន ប៉ុន្តែមានចំណុចរួមតែមួយ គឺដើម្បីផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធទាំងសងខាង។ នៅពីក្រោយការចែកផ្លូវរបស់សហព័ទ្ធទាំងពីរ បានធ្វើឲ្យអ្នកទាំងពីរក្លាយទៅជាអ្នកដទៃនឹងគ្នា មិនត្រឹមតែប៉ុណ្ណោះទេ នៅមានបញ្ហាប្រឈមជាច្រើនតទៀតដូចជា ទំនាក់ទំនងសាច់ញាតិ រវាងគ្រួសារទាំងពីរអាចឈានទៅដល់ការមើមុខគ្នាមិនចំ។ ម្យ៉ាងវិញទៀត ការបែងចែកទ្រព្យសម្បត្តិ ក៏ជាផលប៉ះពាល់ដល់ទំនាក់ទំនងរបស់អ្នកទាំងពីរផងដែរ នៅពេលដែលការបែងចែកនោះ មានភាពមិនស្មើគ្នា ឬមិនមានការព្រមព្រៀងគ្នាឲ្យបានជាក់លាក់ គឺអាចធ្វើឲ្យមានជម្លោះរវាងភាគីទាំងសងខាង។ លើសពីនេះ ទៅទៀតការសម្រេចចិត្តចែកផ្លូវគ្នា អាចជះឥទ្ធិពលទៅដល់អារម្មណ៍របស់កូនផងដែរ នៅពេលដែលតុលាការសម្រេចថាឲ្យជ្រើសរើសរស់នៅជាមួយឪពុក ឬ ម្តាយ។

បញ្ហាប្រឈមដែលកើតឡើងដោយសារតែ បណ្តឹងទាមទារឲ្យមោភាព ឬ លុបចោលអាពាហ៍ពិពាហ៍ ក៏មានវិធីដើម្បីដោះស្រាយផងដែរ ចំពោះបញ្ហាដូចជា ការបែងចែកទ្រព្យសម្បត្តិ បុត្តភាព និង ការផ្តាច់ចំណងគតិយុត្ត ដោយសារតែប្រទេសកម្ពុជា យើងមានច្បាប់មួយចំនួនដែលជាផលប្រយោជន៍សម្រាប់ភាគីទាំងសងខាង នៅពេលដែលមានបណ្តឹងកើតឡើង ហើយច្បាប់ទាំងនោះមានដូចជា ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានជួយការពារផលប្រយោជន៍របស់បុត្តភាព ព្រមទាំងជួយសម្រួលដល់ការបែងចែកទ្រព្យសម្បត្តិរបស់ភាគី និង ងាយស្រួលដល់តុលាការក្នុងការដោះស្រាយវិវាទទាំងនោះ។

សរុបសេចក្តីមក មុនពេលគូស្រករទាំងពីរធ្វើការសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ត្រូវគិតឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការបែកបាក់គ្នាដែលអាចកើតឡើងក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ទោះបីជាមានច្បាប់បានចែកពីបញ្ញត្តិ ដើម្បីជួយការពារផលប្រយោជន៍ក្តី ប៉ុន្តែការបញ្ញត្តិទាំងនោះក៏នៅមានចំណុចខ្វះខាតផងដែរ ហើយអាចនាំភាពស្មុគស្មាញដល់តុលាការនៅពេលដោះស្រាយរឿងក្តីផងដែរ។ ដូចនេះហើយគូស្រករទាំងពីរ មុនធ្វើការសម្រេចចិត្តធ្វើអ្វីមួយ ត្រូវគិតឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការបែកបាក់ ឬ ធ្វើឲ្យបាត់បង់ផលប្រយោជន៍របស់ខ្លួន។

# អនុសាសន៍

ក្រោយការសិក្សាស្រាវជ្រាវ និង ការរៀបចំនូវសារណាបញ្ចប់ការសិក្សារួចមកយើងឃើញថា បណ្តឹងទាមទារឲ្យមោឃភាព និង ការលុបចោលអាពាហ៍ គឺមានចំនួនតិចតួចនៅឡើយ តែទោះបីជាមានចំនួនតិចក្តី ក៏មានប្រជាជនមួយចំនួនមិនទាន់មានការយល់ដឹងអំពីរឿង បណ្តឹងទាមទារឲ្យមោឃភាព និង ការលុបចោលអាពាហ៍ពិពាហ៍នៅឡើយទេ។ ដោយសារតែពុំសូវទទួលបានការផ្សព្វផ្សាយពត៌មាន ឬ ឯកសារច្បាប់ដែលពាក់ព័ន្ធឲ្យបានច្បាស់លាស់ ទើបធ្វើឲ្យគូស្រករ ខ្លះបានរៀបអាពាហ៍ពិពាហ៍ដោយមានការបង្ខិតបង្ខំពីឪពុកម្តាយ ឬ ការរស់នៅអនីតសង្វាសជាមួយគ្នា ឬ ពុំបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវ និង ខុសអពីនីតិវិធីដែលច្បាប់បានញត្តិ ទើបធ្វើឲ្យមានបណ្តឹងកើតឡើង។ មួយវិញទៀត ចំពោះប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាល ដែលមិនបានយល់ដឹងអំពីច្បាប់ ដែលពួកគាត់ធ្វើការរៀបអាពាហ៍ពិពាហ៍ទៅតាមទំនៀមទំលាប់ប្រពៃណីដូនតាដោយមិនបានដឹងអំពីនីតិវិធីច្បាប់ ដែលនាំឲ្យអាពាហ៍ពិពាហ៍គ្មានអានុភាពតាមផ្លូវច្បាប់។

ដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត ព្រមទាំងពុំសូវទទួលបានការផ្សព្វផ្សាយ ឬ ឯកសារច្បាប់ដែលព័ន្ធ ទើបក្រុមយើងខ្ញុំ សូមចូលរួមនូវការផ្តល់មតិយោបល់មួយចំនួនក្នុងគោលបំណងជួយអភិវឌ្ឍន៍សង្គមជាតិ និង កែតម្រូវចំណុចមួយចំនួនដូចជា៖

- រាជរដ្ឋាភិបាល គប្បីធ្វើការផ្សព្វផ្សាយជាសារធារណៈ តាមបណ្តាញសង្គមផ្សេងៗដូចជា ទូរទស្សន៍ វិទ្យុ កាសែត ទស្សនាវត្តី បណ្តាញសង្គមហ្វេសប៊ុក ( Facebook ) តេឡេក្រាម ( Telegram ) ឬចាត់តាំងមន្ត្រីដែលមានជំនាញទៅបង្រៀនដល់មូលដ្ឋានដាច់ស្រយាល ដើម្បីឲ្យប្រជាពលរដ្ឋបានយល់ដឹងច្បាស់អំពីនីតិវិធីនៃការលុបចោល ឬ មោឃអាពាហ៍ពិពាហ៍។
- ប្រជាពលរដ្ឋត្រូវចូលរួមគោរពច្បាប់ជាធរមានឲ្យបានគ្រប់គ្នា ជាពិសេសត្រូវរៀបអាពាហ៍ពិពាហ៍ដោយគោរពទៅតាមច្បាប់ដែលបានបញ្ញត្តិ។
- មុនពេលរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធទាំងពីរ ត្រូវស្មោះស្ម័គ្រជាមួយគ្នា ដោយពុំមានការបង្ខិតបង្ខំពីអ្នកដទៃ ឬ រៀបការដោយគ្មានឆន្ទៈ ដែលនាំឲ្យអាពាហ៍ពិពាហ៍នោះ ឈានដល់មោភាព ឬ លុបចោលអាពាហ៍ពិពាហ៍

# ឯកសារយោង

## ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦
- ច្បាប់ស្តី ពីអាពាហ៍ពិពាហ៍ និង គ្រួសារ, លេខ៥៦ក្រ,២០ ខែកក្កដា ឆ្នាំ ១៩៨៩
- ច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល,លេខ នស/រកម/០៦១០/០០៨, ៨ មិថុនា ២០១០
- ច្បាប់ស្តីពី ឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦,០១ កញ្ញា ២០០៦
- អនុក្រឹត្យស្តីពី អគ្រានុកូលដ្ឋាន, លេខ១០៣ អនក្រ.បក,២៩ ធ្នូ ឆ្នាំ២០០០
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគទី៥. គន្ថីទី៧, ឆ្នាំ២០១០
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃនីតិវិធីក្រមរដ្ឋប្បវេណី, ឆ្នាំ២០០៧
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី, ភាគី១៖នីតិវិធីបណ្តឹង

## សៀវភៅ

- សៀវភៅមេរៀនសង្ខេប នីតិវិធីរដ្ឋប្បវេណី របស់សាស្ត្រចារ្យ លោកមេធាវី អ៊ុំ ប៉ូលី

## សន្ទានុក្រម

- សន្ទានុក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧